## រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សេចក្តីណែនាំបច្ចេកទេស

# ស្តីពី

# ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

ខែមីនា ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ផែនការ

លេខ : ០៧៤ ផក.

ក្រសួងមហាផ្ទៃ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការដាក់ឲ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងតាមស្មារតីកិច្ចប្រជុំលើកទី១៣របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧។

## សម្រេច

**ប្រការ ១.-**

ដាក់ឲ្យប្រើប្រាស់ "**សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**"។

**ប្រការ ២.-**

ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងក្រុមការងារកសាងផែនការខេត្ត ត្រូវរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តឲ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាដោយមានការយកចិត្តទុកដាក់លើបញ្ហាបរិយាប័ន្ន សមធម៌សង្គម និងការប្រែប្រួលអាកាសធាតុ។

**ប្រការ ៣.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រដល់រដ្ឋបាលខេត្ត ដើម្បីឲ្យរដ្ឋបាលខេត្តមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសនេះ សម្រាប់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

# មាតិកា

## ផ្នែកទី១
## ទិដ្ឋភាពទូទៅនៃការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

១. អត្ថន័យនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ១
២. គោលការណ៍ ១
៣. យន្តការ និងភារកិច្ច ១

## ផ្នែកទី២
## ទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

១. ក្របមុខ ៤
២. មាតិកាសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ៥
៣. សេចក្តីពន្យល់អំពីបណ្តាសមាសធាតុនៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ៦

## ផ្នែកទី៣
## វិធីសាស្ត្ររៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

ជំហានទី១ ៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋាន សម្រាប់កសាងកម្មវិធីវិនិយោគ បីឆ្នាំរំកិលខេត្ត ១៤
ជំហានទី២ ៖ ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ១៧
ជំហានទី៣ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ២៨

## ផ្នែកទី៤
## ឧសម្ព័ន្ធជាជំនួយស្មារតី
## នៅពេលរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

ឧបសម្ព័ន្ធទី១ ៖ ទម្រង់សេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ៣០
ឧបសម្ព័ន្ធទី២ ៖ ទម្រង់ជាតុចូល ៣១
ឧបសម្ព័ន្ធទី៣ ៖ វិធីសាស្ត្រចាត់អាទិភាព ៣៦
ឧបសម្ព័ន្ធទី៤ ៖ វិធីសាស្ត្រវិភាគស្ថានភាព ៣៧
ឧបសម្ព័ន្ធទី៥ ៖ ចំណុចគន្លឹះសម្រាប់ក្រុមប្រឹក្សា ៣៨
ឧបសម្ព័ន្ធទី៦ ៖ ជំនួយស្មារតីសម្រាប់ការរៀបចំសរសេរស្ថានភាពទូទៅ ៣៩
ឧបសម្ព័ន្ធទី៧ ៖ ឧបករណ៍វិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ៤៣

# ផ្នែកទី១

# ទិដ្ឋភាពទូទៅនៃការរៀបចំ

# និង

# កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

# និដ្ឋភាពទូទៅ

## នៃការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

## ១. អត្ថន័យនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត គឺជាការដែលធ្វើឱ្យខ្លឹមសារនៃផែនការអភិវឌ្ឍន៍ខេត្តទៅជាសកម្មភាព ឬសេវាជាក់ស្តែង ដោយមានភ្ជាប់នូវចំណាយមូលនិធិ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍនៅក្នុងខេត្តសម្រាប់រយៈពេលបីឆ្នាំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ឆ្លុះបញ្ចាំងពីគម្រោង ឬសេវាជាអាទិភាពនិងតម្លៃតាមបណ្តាឆ្នាំនីមួយៗក្នុងរយៈពេលបីឆ្នាំ ស្របនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលខេត្ត។ពាក្យថា "បីឆ្នាំរំកិល" មានន័យថា កម្មវិធីវិនិយោគត្រូវរៀបចំឡើងសម្រាប់រយៈពេលបីឆ្នាំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ការរៀបចំបែបនេះ នាំមកនូវភាពងាយស្រួលក្នុងការបង្ហាញពីអ្វីដែលបម្រុងនឹងអនុវត្តនៅឆ្នាំខាងមុខ។

គម្រោង សកម្មភាពវិនិយោគ គឺជាគម្រោង សកម្មភាពត្រូវចំណាយមូលនិធិដោយមានពេលចាប់ផ្តើម និងពេលបញ្ចប់ច្បាស់លាស់ ដែលរៀបចំឡើងដើម្បីបង្កើតទ្រព្យសម្បត្តិសាធារណៈ (ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្ត) និងសេវាកម្មសម្រាប់ឆ្លើយតបតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។

## ២. គោលការណ៍

ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវផ្អែកលើគោលការណ៍សំខាន់ដូចខាងក្រោម៖

១. ការចែករំលែកព័ត៌មាន

២. តម្លាភាព

៣. សង្គតិភាព និងសុខដុមនីយកម្ម

៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ

៥. ការឆ្លើយតបនឹងតម្រូវការ

៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៧. ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម

៨. ការធានានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន និង

៩. ការធានាសមធម៌។

## ៣. យន្តការ និងភារកិច្ច

យន្តការ ដែលទទួលខុសត្រូវក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តគឺ ៖

### ៣.១. ក្រុមប្រឹក្សាខេត្ត មានភារកិច្ច ៖

- ចេញសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ពិនិត្យ និងអនុម័តប្រតិទិនរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ចូលរួមក្នុងដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ពិនិត្យ និងអនុម័តសំណើកែតម្រូវកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត (ក្នុងករណីចាំបាច់) និង
- តាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

**៣.២. គណៈអភិបាលខេត្ត** មានភារកិច្ច ៖

- ដឹកនាំ និងសម្របសម្រួលការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ស្របតាមការណែនាំពីក្រុមប្រឹក្សាខេត្ត ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់នានា ក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ដឹកនាំ និងសម្របសម្រួលវេទិកាស្តីពីកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ខេត្ត
- ចូលរួមជាកិត្តិយសក្នុងសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រុង ស្រុក
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត មុនពេលក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័ត
- ដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

**៣.៣. ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខេត្ត** មានភារកិច្ច ៖

- រៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ដឹកនាំ និងសម្របសម្រួលការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់នានាជាមួយបណ្តាភាគីពាក់ព័ន្ធក្នុងការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- រៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

**៣.៤. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត** មានភារកិច្ច ៖

- ចូលរួមរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- សម្របសម្រួលរាល់ការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ពិនិត្យ និងជូនយោបល់ក្រុមប្រឹក្សាខេត្ត មុនធ្វើការអនុម័តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

យន្តការទាំងបួនខាងលើ គឺជាយន្តការស្នូលក្នុងការចូលរួម និងទទួលខុសត្រូវផ្ទាល់លើការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខេត្ត។ ជាមួយគ្នានេះ ដើម្បីធានាឲ្យផែនការអភិវឌ្ឍន៍ខេត្តមានគុណភាពនោះចាំបាច់ត្រូវមានយន្តការគាំទ្រដែលមាន ៖

**៣.៥. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត** មានភារកិច្ច ៖

- ចូលរួមផ្តល់ព័ត៌មាន និងការពារខ្លឹមសារការងារក្នុងដែនសមត្ថកិច្ចខ្លួននៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- សហការបំពេញការងារនានាតាមសំណូមពរពីក្រុមការងារកសាងផែនការខេត្ត ដើម្បីកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

**៣.៦. មន្ទីរផែនការខេត្ត** មានភារកិច្ច ៖

- គាំទ្របច្ចេកទេសកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដូចជា ការងារស្រង់ទិន្នន័យពីមូលដ្ឋានភូមិ ឃុំ សង្កាត់ ការងារចងក្រងកម្រងព័ត៌មានស្ថានភាពខេត្តប្រចាំឆ្នាំ ឯកសារពិន្ទុវិស័យ និងគាំទ្រការងាររៀបចំ និងសម្របសម្រួលក្នុងវេទិកាពិគ្រោះយោបល់ស្តីពីកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

- សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត និងទីចាត់ការផែនការ និងវិនិយោគខេត្ត ក្នុងការបណ្តុះបណ្តាលអំពីបច្ចេកទេសកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ការប្រើប្រាស់ទិន្នន័យ និងបច្ចេកទេសតាមដាន និងវាយតម្លៃលទ្ធផលអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- សហការផ្តល់ការគាំទ្របច្ចេកទេសអំពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត និងការតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តដល់សមាជិកក្រុមប្រឹក្សាខេត្ត និងបុគ្គលិកសំខាន់ៗរបស់ខេត្ត តាមសំណើពីអ្នកពាក់ព័ន្ធ។

**៣.៧. ទីចាត់ការផែនការ និងវិនិយោគខេត្ត** មានភារកិច្ច ៖

- សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត មន្ទីរផែនការខេត្ត និងឬអង្គភាពជំនាញក្នុងការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាខេត្ត ក្រុមការងារកសាងផែនការខេត្ត និងអ្នកពាក់ព័ន្ធអំពីនីតិវិធីកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ជំរុញ និងគាំទ្រការប្រមូល និងរក្សាសៀវភៅកម្មវិធីវិនិយោគទុកជាឯកសារ
- ជួយក្រុមប្រឹក្សាខេត្តក្នុងការរៀបចំ និងអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ព្រមទាំងការតាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

**៣.៨. មន្ទីរជំនាញ និងអង្គភាពនានាជុំវិញខេត្ត** មានភារកិច្ច ៖

- ចូលរួម និងផ្តល់នូវព័ត៌មានជាធាតុចូលដល់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ចូលរួមក្នុងការវិភាគស្ថានភាពខេត្ត និង
- ចូលរួមកិច្ចប្រជុំនានា ស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត និងវេទិកាពិគ្រោះយោបល់ខេត្ត។

**៣.៩. គណៈអភិបាលក្រុង ស្រុក** មានភារកិច្ច ៖

- ចូលរួម និងផ្តល់ព័ត៌មានជាធាតុចូលពាក់ព័ន្ធនឹងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត និង
- ចូលរួមកិច្ចប្រជុំនានាស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត និងវេទិកាពិគ្រោះយោបល់ខេត្តតាមការចាំបាច់។

**៣.១០. អង្គការសង្គមស៊ីវិល ក្រុមយុវជន និងវិស័យឯកជន** មានភារកិច្ច ៖

- ចូលរួម និងផ្តល់នូវព័ត៌មាននានាដែលពាក់ព័ន្ធនឹងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ចូលរួមក្នុងការវិភាគស្ថានភាពខេត្ត និង
- ចូលរួមកិច្ចប្រជុំនានាដែលពាក់ព័ន្ធដល់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត និងវេទិកាពិគ្រោះយោបល់ខេត្ត។

# ផ្នែកទី២

# ទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**១ .គ្របមុខ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កម្មវិធីវិនិយោគបីឆ្នាំរំកិល

# ២០....២០ - ....

# ខេត្ត......................

បានទទួលការអនុម័តពីក្រុមប្រឹក្សាខេត្ត
ក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញ លើកទី ថ្ងៃទី ខែ ឆ្នាំ២០...

## ២. មាតិកាសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**

**អារម្ភកថា**

**សេចក្តីផ្តើម**

**ផែនទី**

**ជំពូកទី១ ÷ ស្ថានភាពទូទៅ និងបញ្ហាប្រឈម**

១.១.សេចក្តីសង្ខេបទិន្នន័យចម្បងរបស់ខេត្ត

១.២.ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

- ផ្នែកសេដ្ឋកិច្ច
- ផ្នែកសង្គមកិច្ច
- ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

**ជំពូកទី២ ÷ គម្រោង សកម្មភាព នៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**

២.១. តារាងសង្ខេបប្រភពមូលនិធិ

២.២. តារាងគម្រោង សកម្មភាពកំពុងដំណើរការ

២.៣. តារាងគម្រោង សកម្មភាពវិនិយោគមានថវិកាគាំទ្រ

២.៤. តារាងគម្រោង សកម្មភាពអាទិភាពមិនទាន់មានថវិកាគាំទ្រ

២.៥. តារាងកម្មវិធីប្រតិបត្តិការសេវារដ្ឋបាល

២.៦. តារាងការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា

២.៧. តារាងគម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័នកំពុងដំណើរការ

**ជំពូកទី៣ ÷ ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**

៣.១. ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ

៣.២. ការបែងចែកភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការតាមដាន និងវាយតម្លៃ

៣.៣. របាយការណ៍ស្តីពីលទ្ធផលតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**ឧបសម្ព័ន្ធ**

## ៣. សេចក្តីពន្យល់
## អំពីបណ្តាសមាសធាតុក្នុងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**

បន្ទាប់ពីទំព័រក្របសៀវភៅ គឺសេចក្តីសម្រេច។ សេចក្តីសម្រេច គឺជាលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាខេត្ត ក្នុងការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។ ខ្លឹមសារសំខាន់ក្នុងសេចក្តីសម្រេចរួមមានការចូលជាធរមាននូវកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ការណែនាំដល់គណៈអភិបាលខេត្តឲ្យធ្វើការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។ សេចក្តីសម្រេចនេះចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខេត្ត។

**អារម្ភកថា**

អារម្ភកថា គឺជាអត្ថបទបង្ហាញពីសារៈប្រយោជន៍នៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ការថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល និងសេចក្តីសង្ឃឹមថានឹងទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធ (អារម្ភកថាមិនគួរសរសេរវែងពេក ត្រឹមមួយទំព័រគឺជាការប្រសើរ)។

**សេចក្តីផ្តើម**

សេចក្តីផ្តើម ត្រូវសរសេរពីវឌ្ឍនភាពនៅក្នុងខេត្ត និងមូលហេតុដែលនាំឲ្យមានការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ព្រមទាំងគោលបំណង និងសង្ខេបពីដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (សេចក្តីផ្តើមគួរសរសេរខ្លីដែរ)។

**ផែនទី**

ជាផែនទីខេត្ត ដែលបង្ហាញពីលក្ខណៈភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និងទីតាំងរដ្ឋបាលក្នុងខេត្ត។ ផែនទីនេះរៀបចំលើក្រដាសទំហំA3 និងប្រើនិមិត្តសញ្ញាតាងឱ្យវត្ថុកំពុងមានក្នុងខេត្ត ដូចជានិមិត្តសញ្ញានៃប្រព័ន្ធផ្លូវថ្នល់ ស្ពាន លូរំដោះទឹក ប្រព័ន្ធប្រឡាយទឹក ទីតាំងរដ្ឋបាល ទីតាំងសាលារៀន ទីតាំងផ្តល់សេវាសុខភាពសាធារណៈ ទីតាំងសាសនា វាលស្រែ ធនធានធម្មជាតិ ។ល។

## ជំពូកទី១ ÷ ស្ថានភាពទូទៅ និងបញ្ហាប្រឈមក្នុងខេត្ត

### ១.១. សេចក្តីសង្ខេបទិន្នន័យចម្បងរបស់ខេត្ត

សេចក្តីសង្ខេបទិន្នន័យចម្បងរបស់ខេត្ត ត្រូវបានបង្ហាញតាមបែបវិភាគក្នុងតារាងខាងក្រោម៖

**តារាងសង្ខេបទិន្នន័យចម្បងរបស់ខេត្ត**

| ល.រ | បរិយាយ | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... |
|---|---|---|---|---|---|---|
| **ព័ត៌មានទូទៅ** | | | | | | |
| ១ | ផ្ទៃដីខេត្ត (គ.ម$^{២}$ ) | | | | | |
| ២ | ចំនួនក្រុង ស្រុក | | | | | |
| ៣ | ចំនួនឃុំ សង្កាត់ | | | | | |
| ៤ | ចំនួនភូមិ | | | | | |
| ៥ | ចំនួនគ្រួសារ | | | | | |
| ៦ | % មេគ្រួសារជាស្ត្រី | | | | | |
| ៧ | ចំនួនប្រជាជនសរុប | | | | | |
| ៨ | ចំនួនស្រី | | | | | |

| ល.រ | បរិយាយ | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... |
|---|---|---|---|---|---|---|
| ៩ | ចំនួនប្រុស | | | | | |
| ១០ | % អ្នកមានអាយុពី០-១៧ឆ្នាំ | | | | | |
| ១១ | % អ្នកមានអាយុពី១៨-៦០ឆ្នាំ | | | | | |
| ១២ | % អ្នកមានអាយុពី៦១ឆ្នាំឡើង | | | | | |
| ១៣ | កំណើនប្រជាជនប្រចាំឆ្នាំ (%) | | | | | |
| ១៤ | អត្រាភាពក្រីក្រ (%) | | | | | |
| ១៥ | % អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | | | | | |
| ១៦ | % អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | | | | | |
| ១៧ | % អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | | | | | |
| ១៨ | % មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | | | | | |
| ១៩ | % មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | | | | | |
| ២០ | % ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់ | | | | | |
| **អប់រំ** | | | | | | |
| ២១ | % កុមារអាយុ៣-៥ឆ្នាំបានចូលរៀន | | | | | |
| ២២ | % កុមារអាយុ៦ឆ្នាំបានចូលរៀន | | | | | |
| ២៣ | % កុមារអាយុ៦-១១ឆ្នាំបានចូលរៀន | | | | | |
| ២៤ | % កុមារអាយុ១២-១៤ឆ្នាំនៅរៀន | | | | | |
| ២៥ | % អ្នកចេះអក្សរអាយុ១៥-១៧ឆ្នាំ | | | | | |
| ២៦ | % អ្នកចេះអក្សរអាយុ១៨-៤៥ឆ្នាំ | | | | | |
| **សុខភាព** | | | | | | |
| ២៧ | ចំនួនមណ្ឌលសុខភាព | | | | | |
| ២៨ | % ស្ត្រីសម្រាលកូនដោយឆ្មបពេទ្យ | | | | | |
| ២៩ | អត្រាស្លាប់របស់មាតាក្រោយពេលសម្រាល(០-១ខែ) ក្នុង១ពាន់កំណើត | | | | | |
| ៣០ | អត្រាស្លាប់របស់កុមារក្រោយពេលកើត(០-១ខែ)ក្នុង១ពាន់កំណើត | | | | | |
| ៣១ | % កុមារអាយុពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | | | | | |
| ៣២ | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | | | | | |
| **ភាពងាយរងគ្រោះ** | | | | | | |
| ៣៣ | ចំនួនជនពិការ | | | | | |
| ៣៤ | % ជនពិការអាយុ១៨ឆ្នាំឡើងមិនអាចរកចំណូលបាន | | | | | |
| ៣៥ | ចំនួនកុមារកំព្រាឪពុកម្ដាយស្លាប់ដោយជំងឺអេដស៍ | | | | | |
| ៣៦ | ចំនួនចាស់ជរាគ្មានទីពឹង(អាយុ៦១ឆ្នាំឡើង) | | | | | |
| **ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ** | | | | | | |
| ៣៧ | ចំនួនគ្រួសាររងគ្រោះដោយខ្យល់ព្យុះ/កន្ត្រាក់ | | | | | |
| ៣៨ | ចំនួនគ្រួសាររងគ្រោះដោយទឹកជំនន់ | | | | | |
| ៣៩ | ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត | | | | | |
| ៤០ | % គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | | | | | |
| ៤១ | % គ្រួសារមានទឹកស្អាតប្រើប្រាស់ | | | | | |
| | % គ្រួសារមានទឹកម៉ាស៊ីនប្រើប្រាស់ | | | | | |

| ល.រ | បរិយាយ | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... |
|---|---|---|---|---|---|---|
| ក្នុងនោះ | % គ្រួសារមានទឹកអណ្តូងស្នប់ឬអណ្តូងចម្រុះ | | | | | |
| | % គ្រួសារប្រើទឹកអណ្តូងជីកមានការការពារ | | | | | |
| | % គ្រួសារប្រើទឹកភ្លៀងមានការការពារ | | | | | |
| ៤២ | % គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | | | | | |
| **រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | | |
| ៤៣ | % កុមារបានចុះសំបុត្រកំណើត(០-៣០ថ្ងៃ) | | | | | |
| ៤៤ | ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | | | | | |
| ៤៥ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | | | | | |
| ៤៦ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | | | | | |
| ៤៧ | ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | | | | | |

### ១.២.ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមក្នុងខេត្ត

ផ្នែកនេះ ត្រូវសរសេរតាម**បែបវិភាគ**អំពីបច្ចុប្បន្នភាពនៃស្ថានភាពនានា និងកំណត់យកដំណោះស្រាយបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងផែនការអភិវឌ្ឍន៍ខេត្ត។ ការអធិប្បាយ និងសរសេរត្រូវធ្វើតាមលំដាប់លំដោយដោយផ្តើមពីស្ថានភាពសេដ្ឋកិច្ច ទៅស្ថានភាពសង្គមកិច្ច ស្ថានភាពប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិបរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុរហូតដល់ស្ថានភាពគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ(ឧបសម្ព័ន្ធទី៦)។ ក្នុងការសរសេរផ្នែកនេះ ក្រុមការងារកសាងផែនការត្រូវយកព័ត៌មានស្តីពីលទ្ធផលនៃការវិភាគពិន្ទុវិស័យ និងស្ថានភាពខេត្តធ្វើជាមូលដ្ឋាន។

## ជំពូកទី២ ÷ គម្រោង សកម្មភាព នៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

ផ្តើមដោយអត្ថបទដែលបរិយាយសង្ខេបពីតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍនៅឆ្នាំខាងមុខ។ បន្ទាប់មក ត្រូវរៀបចំបណ្តាតារាងគម្រោង សកម្មភាពវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត ដែលមានជាអាទិ៍ ៖

**តារាង២.១. សង្ខេបប្រភពមូលនិធិឆ្នាំ.........**

| ល.រ | ស្ថាប័ន | ចំនួនគម្រោង | សរុបតម្លៃគម្រោង (លានរៀល) | ប្រភពមូលនិធិ | ចំនួនគម្រោង | តម្លៃគម្រោង (លានរៀល) |
|---|---|---|---|---|---|---|
| ១ | រដ្ឋបាលខេត្ត | | | ខេត្ត | | |
| | | | | ដៃគូអភិ. | | |
| | | | | សប្បុរសជន | | |
| ២ | ការគាំទ្រតាមបណ្តាមន្ទីរ អង្គភាព | | | | | |
| ២.១ | មន្ទីរ... | | | មន្ទីរ | | |
| | | | | ដៃគូអភិ. | | |
| ២.២ | មន្ទីរ... | | | មន្ទីរ | | |
| | | | | ដៃគូអភិ. | | |
| ... | ... | | | មន្ទីរ | | |
| | | | | ដៃគូអភិ. | | |
| សរុបមន្ទីរអង្គភាព | | | | មន្ទីរ | | |
| | | | | ដៃគូអភិ. | | |
| **សរុបរួម** (១+២) | | | | | | |

## តារាង២.២ ÷ គម្រោង សកម្មភាពខេត្តកំពុងដំណើរការ

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃ | ប្រភពមូលនិធិ | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | ២... | ២... | ២... | សរុប | | |
| **ក.គម្រោង សកម្មភាពរបស់រដ្ឋបាលខេត្ត** | | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| **ខ.គម្រោង សកម្មភាពរបស់មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធ** | | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

**កំណត់សម្គាល់ ៖** ជាតារាងដែលបង្ហាញពីប្រភេទគម្រោង សកម្មភាពកំពុងអនុវត្តក្នុងឆ្នាំរៀបចំកម្មវិធី ឬឆ្នាំសារពើពន្ធថវិកា ហើយនឹងត្រូវបន្តអនុវត្តនៅឆ្នាំមុខទៀត។

### តារាង២.៣ ÷ គម្រោង សកម្មភាពវិនិយោគខេត្តមានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃ | ប្រភពមូលនិធិ | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | ២... | ២... | ២... | សរុប | |
| **ក.គម្រោង សកម្មភាពរបស់រដ្ឋបាលខេត្ត** | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| **ខ.គម្រោង សកម្មភាពរបស់មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធ** | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

**កំណត់សម្គាល់ ៖** ជាតារាងដែលបង្ហាញពីប្រភេទគម្រោង សកម្មភាពដែលប្រើប្រាស់ថវិកាខេត្ត និងប្រើប្រាស់ថវិកាដែលទទួលបានការគាំទ្រពីមន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។

### តារាង២.៤ ÷ គម្រោង សកម្មភាពខេត្តមានអាទិភាពដែលមិនទាន់មានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេល អនុវត្ត | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន (លានរៀល) | អង្គភាពស្នើ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

### តារាង២.៥. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល ឆ្នាំ.......

| ល.រ | ប្រភេទសេវា | លទ្ធផលគ្រោង | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|
| | | បរិមាណ | ឯកតា | | |
| **ក. កម្មវិធីផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលខេត្ត** | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| **ខ. កម្មវិធីផ្តល់សេវារដ្ឋបាលរបស់មន្ទីរ អង្គភាព** | | | | | |
| មន្ទីរ....... | | | | | |
| | | | | | |
| | | | | | |
| មន្ទីរ....... | | | | | |
| | | | | | |
| | | | | | |

**កំណត់សម្គាល់ ៖** កម្មវិធីផ្តល់សេវាកម្មរបស់រដ្ឋបាលខេត្ត ឬរបស់មន្ទីរ អង្គភាព គឺជាសកម្មភាពផ្តល់សេវារដ្ឋបាលនានាជាប្រចាំរបស់រដ្ឋបាលខេត្ត ឬរបស់មន្ទីរ អង្គភាពជូនប្រជាពលរដ្ឋរបស់ខ្លួន រួមបញ្ចូលទាំងការអនុវត្តមុខងារ និងធនធាននានា ដែលបានទទួល។

### តារាង២.៦. លិខិតបទដ្ឋាននានារបស់រដ្ឋបាលខេត្តដែលនឹងរៀបចំដាក់ឲ្យប្រើប្រាស់ នៅឆ្នាំ.....

| ល.រ | ប្រភេទលិខិតបទដ្ឋាន | លទ្ធផលគ្រោង | | ផ្សេងៗ |
|---|---|---|---|---|
| | | បរិមាណ | ឯកតា | |
| | | | | |
| | | | | |
| | | | | |
| | | | | |

### តារាង២.៧ ÷ គម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័ន កំពុងអនុវត្តក្នុងដែនភូមិសាស្ត្រខេត្ត

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃ | ប្រភពមូលនិធិ | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | |
| ១. ក្រសួង... | | | | | | | | |
| ១ | | | | | | | | |
| ២ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| ២. ក្រសួង... | | | | | | | | |
| ១ | | | | | | | | |
| ២ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

## ជំពូកទី៣ ÷  ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺជាសកម្មភាពផ្តោតលើការសន្និដ្ឋានពីស្ថានភាព និងលទ្ធផលនៃការអនុវត្ត ៖

- គម្រោង សកម្មភាពកំពុងអនុវត្ត
- គម្រោង សកម្មភាពមានថវិកាគាំទ្រ
- គម្រោង សកម្មភាពអាទិភាពមិនទាន់មានការសន្យាគាំទ្រ
- តើមានការគាំទ្រគម្រោង សកម្មភាពថ្មីបន្ថែមក្រៅពីគម្រោង សកម្មភាពមិនទាន់មានការសន្យាគាំទ្របុទេ ?។ល។
- កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល
- ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា

**តារាង២.៨. តាមដានការអនុវត្តកម្មវិធីវិនិយោគខេត្ត**

| លរ. | ឈ្មោះគម្រោង | គ្រោង/ជាក់ស្តែង | លទ្ធផល | | រយៈពេលអនុវត្ត | តម្លៃគម្រោង | អង្គភាពអនុវត្ត | % នៃការសម្រេច | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | | |
| **គម្រោងរបស់រដ្ឋបាលខេត្ត** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **គម្រោងរបស់មន្ទីរ អង្គភាព** | | | | | | | | | |
| **មន្ទីរ អង្គភាព**......... | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការអនុវត្តកម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់រដ្ឋបាលខេត្ត** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការអនុវត្តកម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់មន្ទីរ អង្គភាព** | | | | | | | | | |
| **មន្ទីរ អង្គភាព**... | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការដាក់ចេញលិខិតបទដ្ឋាននានារបស់រដ្ឋបាលខេត្ត** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |

**ឧបសម្ព័ន្ធ ៖** ក្នុងការរៀបចំផ្នែកឧបសម្ព័ន្ធនៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុមការងារកសាងផែនការខេត្តអាចពិចារណាដាក់បញ្ចូលនូវតារាង ឬព័ត៌មានពាក់ព័ន្ធនានាតាមការចាំបាច់។

# ផ្នែកទី៣

## វិធីសាស្ត្ររៀបចំ និង
## កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

# ជំហានទី១
## ការប្រមូលព័ត៌មានស្តីពីតម្រូវការ
## របស់មូលដ្ឋានសម្រាប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**គោលបំណង**

គោលបំណងនៃជំហានទី១នេះ គឺការប្រមូលតម្រូវការអភិវឌ្ឍន៍នានារបស់ខេត្ត ដើម្បីធ្វើជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាខេត្ត គម្រោងថវិកាប្រចាំឆ្នាំខេត្ត និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

**លទ្ធផលរំពឹងទុក**

បញ្ជីគម្រោង សកម្មភាព ដែលមានតម្លៃប៉ាន់ស្មានទាំងផ្នែករូបវន្ត អរូបវន្ត ជាតម្រូវការរបស់ប្រជាពលរដ្ឋ ដែលខេត្តមានបំណងសម្រេចឲ្យបាននៅឆ្នាំខាងមុខ ត្រូវបានប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាខេត្ត និងគម្រោងថវិកាប្រចាំឆ្នាំខេត្ត។

**ដំណើរការ**

សកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តក្នុងជំហានទី១នេះ រួមមាន ៖

១.១. ប្រជុំណែនាំពីការប្រមូលតម្រូវការអាទិភាព

១.២. ប្រជុំបូកសរុបតម្រូវការគម្រោង សកម្មភាព និងចាត់អាទិភាព

**១.១. ប្រជុំណែនាំពីការប្រមូលតម្រូវការអាទិភាព**

ដើម្បីមានព័ត៌មានជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាខេត្ត ក្រុមការងារកសាងផែនការខេត្ត ត្រូវរៀបចំកិច្ចប្រជុំណែនាំពីការប្រមូលតម្រូវការអាទិភាពសម្រាប់ការអភិវឌ្ឍន៍ខេត្ត ដល់អ្នកពាក់ព័ន្ធក្នុងខេត្ត។

**សមាសភាពចូលរួម**

- គណៈអភិបាលខេត្ត
- តំណាងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- ប្រធានមន្ទីរ អង្គភាពនានាជុំវិញខេត្ត
- ក្រុមការងារកសាងផែនការខេត្ត
- នាយកទីចាត់ការនានារបស់រដ្ឋបាលខេត្ត
- អភិបាលក្រុង ស្រុក
- តំណាងក្រុមការងារកសាងផែនការក្រុង ស្រុក និង
- អ្នកពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។ល។

**កិច្ចដំណើរការប្រជុំណែនាំ**

- អភិបាលខេត្ត ឬតំណាង បើក និងដឹកនាំអង្គប្រជុំ។
- ដោយមានការអនុញ្ញាតពីប្រធានអង្គប្រជុំ តំណាងក្រុមការងារកសាងផែនការខេត្ត ធ្វើបទបង្ហាញពី ៖
  - តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត
  - គោលបំណងនៃការប្រមូលតម្រូវការអាទិភាពសម្រាប់ការអភិវឌ្ឍន៍មូលដ្ឋានខេត្ត
  - មូលដ្ឋានព័ត៌មានសម្រាប់គាំទ្រដល់ការប្រមូលតម្រូវការអាទិភាពសម្រាប់ការអភិវឌ្ឍន៍មូលដ្ឋានខេត្ត (ព័ត៌មានពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចខេត្ត ពិន្ទុវិស័យរបស់ខេត្ត និងអត្រាភាពក្រីក្ររបស់ខេត្ត...)
  - ទម្រង់ និងខ្លឹមសាររបស់ទម្រង់ទី១ (ឧបសម្ព័ន្ធទី២ ក្នុងផ្នែកទី៤)

- វិធីសាស្ត្រចាត់អាទិភាព (ឧបសម្ព័ន្ធទី២ ក្នុងផ្នែកទី៤)
- លក្ខណៈវិនិច្ឆ័យនៃគម្រោងដែលត្រូវស្នើដើម្បីដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគខេត្ត (ចំណុច "ខ" នៃទម្រង់ទី១ គឺជាគម្រោង ឬសកម្មភាពដែល ៖
  + ឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត
  + ស្ថិតនៅក្នុងដែនសមត្ថកិច្ចខេត្ត
  + គម្រោងដែលមានលក្ខណៈអន្តរក្រុង ស្រុក
- ចំនួនអតិបរមានៃគម្រោង សកម្មភាពស្នើរបស់សាមីអង្គភាព
- កាលបរិច្ឆេទនៃការបញ្ជូនតារាងតម្រូវការគម្រោង សកម្មភាពអាទិភាព បានបំពេញមកឲ្យក្រុមការងារកសាងផែនការខេត្ត។

បន្ទាប់ពីការធ្វើបទបង្ហាញ ប្រធានអង្គប្រជុំបើកការពិភាក្សា និងពន្យល់ បំភ្លឺ បូកសរុប ផ្តាំផ្ញើ និងបិទកិច្ចប្រជុំផ្សព្វផ្សាយ។

បន្ទាប់ពីចូលរួមកិច្ចប្រជុំណែនាំនៅខេត្ត រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក មន្ទីរ អង្គភាពក្នុងខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ត្រូវវិភាគស្ថានភាព (ឧបសម្ព័ន្ធទី៤ និងទី៨ ក្នុងផ្នែកទី៤) និងកំណត់យកតែតម្រូវការណាដែលមានអាទិភាពសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន និងវិស័យជំនាញមកបំពេញតារាងតម្រូវការគម្រោង សកម្មភាពអាទិភាពរបស់ខ្លួន រួចបញ្ជូនទៅក្រុមការងារកសាងផែនការខេត្តឲ្យបានទាន់ពេលកំណត់។

**១.២.ប្រជុំបូកសរុបតម្រូវការគម្រោង សកម្មភាព និងចាត់អាទិភាព**

**១.២.១. សកម្មភាពមុនដំណើរការប្រជុំ**

បន្ទាប់ពីទទួលបាន តារាងតម្រូវការគម្រោង សកម្មភាពអាទិភាព (ទម្រង់ទី១) ពីរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក មន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនាននាក្នុងខេត្ត ក្រុមការងារកសាងផែនការខេត្ត ត្រូវ ៖

- ធ្វើការប្រជុំបូកសរុប តម្រូវការគម្រោង សកម្មភាពជាអាទិភាពទាំងនោះ ដោយត្រូវពិនិត្យខ្លឹមសារគម្រោង សកម្មភាពទាំងនោះថា តើមានសង្គតិភាពជាមួយគោលដៅអភិវឌ្ឍន៍ក្នុងផែនការអភិវឌ្ឍន៍ខេត្តដែរឬទេ? បើគ្មានសង្គតិភាព ត្រូវពិគ្រោះជាមួយអង្គភាពសាមី។
- ពិចារណាពីភាពសមស្របរវាងខ្លឹមសារគម្រោង សកម្មភាពជាមួយតួនាទី លទ្ធភាព សមត្ថភាពរបស់អង្គភាពមានតម្រូវការ និងចៀសវាងការបូកសរុបត្រួតគ្នា ភាពមិនច្បាស់ឈ្មោះគម្រោង ឬសកម្មភាព
- ក្រុមការងារកសាងផែនការខេត្តត្រូវពិនិត្យគម្រោងសំណើទាំងអស់ដែលបានទទួល ដើម្បីរៀបចំតារាង ១.១.ក ដោយត្រូវកំណត់តាមលំដាប់លំដោយដូចខាងក្រោម ៖

**ក.** រៀបចំតម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគខេត្ត ដោយពិនិត្យលើ ៖

- សំណើគម្រោង(ចំណុច"ខ"នៃទម្រង់ទី១)ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចបានកំណត់
- គម្រោងអាទិភាពកាលពីឆ្នាំកន្លងទៅ ហើយមិនបានអនុវត្ត ថាតើគម្រោងទាំងនោះនៅតែជាតម្រូវការអាទិភាពឬទេ? ប្រសិនបើនៅតែជាតម្រូវការអាទិភាព ក្រុមការងារកសាងផែនការខេត្តត្រូវស្រង់គម្រោងទាំងនោះចូលក្នុងផ្នែក "ក" នៃតារាង១.១.ក
- គម្រោង ឬសកម្មភាពនានាដើម្បីអនុវត្តមុខងារជាកាតព្វកិច្ច និងឬមូលនិធិមានភ្ជាប់លក្ខខណ្ឌនានា ដែលរដ្ឋបាលខេត្តបានទទួល
- តម្រូវការដាក់ស្តែងបន្ថែមទៀត ដើម្បីឆ្លើយតបគោលដៅអភិវឌ្ឍន៍នានា ដែលបានកំណត់

**ខ.** តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគក្រុង ស្រុក ដោយ ៖

- ពិនិត្យមើលគម្រោង សកម្មភាពនានាដែលបានស្នើបញ្ចូលក្នុងកម្មវិធីវិនិយោគខេត្ត ហើយដែលសមស្របនឹងតួនាទី សមត្ថភាព លទ្ធភាពអនុវត្តរបស់ក្រុង ស្រុក ក្រុមការងារកសាង

ផែនការខេត្តត្រូវស្រង់គម្រោងទាំងនោះចូលក្នុងតារាង១.១.ក ចំណុច "ខ" គម្រោង សកម្មភាពសម្រាប់កម្មវិធីវិនិយោគក្រុង ស្រុក

- ពិនិត្យមើលព័ត៌មាននៅក្នុងទម្រង់ទី១ ចំណុច "ក" ដែលបានទទួលពីរដ្ឋបាលក្រុង ស្រុក

**គ.** ចំពោះគម្រោង សកម្មភាពសមស្របតាមតួនាទី សមត្ថភាព លទ្ធភាពអនុវត្តរបស់ឃុំ សង្កាត់ ក្រុមការងារកសាងផែនការខេត្តត្រូវស្រង់គម្រោងទាំងនោះចូលក្នុងតារាង១.១.ក ចំណុច "គ" គម្រោងសកម្មភាពសម្រាប់កម្មវិធីវិនិយោគឃុំ សង្កាត់។

**ឃ.** ចំពោះគម្រោង សកម្មភាពដែលមិនស្របនឹងតួនាទីរបស់រដ្ឋបាលខេត្ត ឬសមស្របតាមតួនាទីខេត្ត ប៉ុន្តែហួសសមត្ថភាព លទ្ធភាពអនុវត្តរបស់ខេត្ត នឹងត្រូវសុំការគាំទ្រពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានានៅថ្នាក់ជាតិ ក្រុមការងារកសាងផែនការខេត្តត្រូវស្រង់គម្រោងទាំងនោះចូលក្នុង តារាងមួយដោយឡែកសម្រាប់បញ្ជូនទៅក្រសួង ស្ថាប័នដែលពាក់ព័ន្ធ។

- រៀបចំប្រជុំជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងផ្តល់យោបល់លើតារាងសំណើគម្រោងខាងលើ។
- ក្រុមការងារកសាងផែនការខេត្ត ត្រូវជូនដំណឹងទៅក្រុមការងារកសាងផែនការក្រុង ស្រុកនីមួយៗ អំពីការកែសម្រួល ឬការផ្លាស់ប្តូរគម្រោងក្នុងចំណុច "ខ" និងចំណុច "គ" ខាងលើ។

តារាង១.១.ក ៖ តារាងតម្រូវការគម្រោង សកម្មភាពអាទិភាពទូទាំងខេត្ត

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | ផ្នែក | អង្គភាពស្នើ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | | |
| ក ៖ តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគខេត្ត | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ខ ៖ តម្រូវការគម្រោងដែលស្រុក ស្នើសុំបញ្ចូលទៅក្នុងកម្មវិធីវិនិយោគក្រុង ស្រុក | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| គ ៖ គម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគឃុំ សង្កាត់ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

**<u>សម្គាល់ ៖</u>**

កូឡោន "ផ្នែក" ត្រូវបញ្ជាក់ថា គម្រោងនីមួយៗនោះ ស្ថិតក្នុងក្របខ័ណ្ឌនៃផ្នែកណា ក្នុងចំណោមផ្នែកទាំង៤ ដូចខាងក្រោម ៖

- I. សំដៅលើ "ផ្នែកសេដ្ឋកិច្ច"
- II. សំដៅលើ "ផ្នែកសង្គមកិច្ច"
- III. សំដៅលើ "ផ្នែកធនធានធម្មជាតិ និងបរិស្ថាន"
- IV. សំដៅលើ "ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ"

បន្ទាប់ពីរៀបចំបញ្ចប់តារាង១.១.ក ខាងលើ អភិបាលខេត្តត្រូវចាត់ចែងបញ្ជូនតារាងនេះ ទៅក្រុមការងារពាក់ព័ន្ធនឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាខេត្ត។

## ជំហានទី២

## ការរៀបចំសេចក្ដីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**គោលបំណង**

គោលបំណងនៃជំហានទី២នេះ គឺការរៀបចំ និងចងក្រងសេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តដោយមានភាពជាក់លាក់ មានការចូលរួម អាចអនុវត្តបាន និងមានសង្គតិភាពជាមួយនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត។

**លទ្ធផលរំពឹងទុក**

សេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវបានបញ្ចប់ និងដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័ត។

**សកម្មភាពអនុវត្ត**

ក្នុងជំហានទី២នេះ សកម្មភាពសំខាន់ដែលត្រូវអនុវត្តមាន ៖

២.១. កិច្ចប្រជុំផ្សព្វផ្សាយសេចក្ដីណែនាំស្ដីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

២.២. ការពិនិត្យ និងចាត់អាទិភាពគម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តឡើងវិញ

២.៣. រៀបចំវេទិកាពិគ្រោះយោបល់ក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

២.៤. ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅតាមបណ្ដាក្រុង ស្រុក

២.៥. ចងក្រងសេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

២.៦. ការរៀបចំការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល

២.៧. ការពិនិត្យ និងផ្ដល់យោបល់

### ២.១. កិច្ចប្រជុំផ្សព្វផ្សាយសេចក្ដីណែនាំស្ដីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**គោលបំណង**

គោលបំណងនៃកិច្ចប្រជុំនេះ គឺឲ្យអ្នកពាក់ព័ន្ធបានយល់ពីខ្លឹមសារនៃសេចក្ដីណែនាំស្ដីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត បានយល់ពីខ្លឹមសារលិខិតបទដ្ឋាននានា កញ្ចប់ថវិកាប្រចាំឆ្នាំ សារៈសំខាន់នៃការចូលរួម និងចូលរួមកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

**លទ្ធផលរំពឹងទុក**

លទ្ធផលរំពឹងទុកពីសកម្មភាពនេះ មាន ៖

- គ្រប់ភាគីពាក់ព័ន្ធក្ដាប់បានពីគោលបំណង នៃសេចក្ដីណែនាំស្ដីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- គ្រប់ភាគីពាក់ព័ន្ធទទួលបានការណែនាំពីនីតិវិធីនៃការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តដោយបានយល់ និងចេះបំពេញបណ្ដាតារាងខាងក្រោម ៖
  - តារាងគម្រោង សកម្មភាពមានថវិកាគាំទ្រ
  - តារាងគម្រោង សកម្មភាពកំពុងដំណើរការ
  - តារាងគម្រោង សកម្មភាពមិនមានថវិកាគាំទ្រ
  - តារាងគម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័នកំពុងដំណើរការក្នុងដែនដីខេត្ត
  - តារាងគម្រោង សកម្មភាពរបស់អង្គការជាតិ អន្តរជាតិ និងវិស័យឯកជនកំពុងដំណើរការក្នុងដែនដីខេត្ត
  - តារាងគម្រោង សកម្មភាពវិនិយោគដែលបានបញ្ចប់។ល។

**ដំណើរការ**

**ក). មុនកិច្ចប្រជុំផ្សព្វផ្សាយ**

សកម្មភាពដែលត្រូវអនុវត្តមុនកិច្ចប្រជុំផ្សព្វផ្សាយ រួមមាន ៖

- ក្រុមការងារកសាងផែនការខេត្តត្រូវសុំកិច្ចសហការ និងគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត ធ្វើការតាក់តែងសេចក្តីព្រាងសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត (ឧបសម្ព័ន្ធទី១ ក្នុងផ្នែកទី៤) ជូនអភិបាលខេត្តពិនិត្យ និងផ្តល់យោបល់ រួចដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័ត។ សេចក្តីណែនាំនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខេត្ត។ ខ្លឹមសារនៃសេចក្តីណែនាំស្តីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត មាន ៖
  - ការវាយតម្លៃលើស្ថានភាពទូទៅរបស់ខេត្ត
  - ទិសដៅអភិវឌ្ឍន៍ចម្បងនានារបស់ខេត្តសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តខាងមុខ
  - វិធីសាស្ត្រ និងតួនាទីរបស់អ្នក ឬអង្គភាពពាក់ព័ន្ធក្នុងដំណើរប្រព្រឹត្តទៅនៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
  - ប្រតិទិនការងារ

> **បញ្ជាក់ ៖** ក្នុងការវាយតម្លៃលើស្ថានភាពទូទៅរបស់ខេត្ត ក្រុមការងារកសាងផែនការខេត្ត ត្រូវធ្វើការវិភាគទៅលើ ទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច និងស្ថានភាពបច្ចុប្បន្ន ក៏ដូចជាបញ្ហាប្រឈមរបស់ខេត្ត។ សម្រាប់កម្មវិធីវិនិយោគបីឆ្នាំ រំកិលលើកទី១នៃអាណត្តិក្រុមប្រឹក្សា ការរៀបចំខ្លឹមសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ត្រូវផ្អែកតាមលទ្ធផលនៃការ វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្ត។ សម្រាប់ឆ្នាំបន្តបន្ទាប់ ការរៀបចំ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពដោយផ្អែកលើការប្រែប្រួលសំខាន់ៗ ដែលកើតមានឡើងក្រោយពីផែនការអភិវឌ្ឍន៍ខេត្ត ត្រូវបានដាក់ឲ្យប្រើប្រាស់។ ត្រូវប្រើប្រាស់ឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ឯកសារពិន្ទុវិស័យ ឯកសាររបស់មន្ទីរ អង្គភាពជំនាញក្នុងខេត្ត និងឯកសារពាក់ព័ន្ធដ៏ទៃទៀតក្នុងការរៀបចំខ្លឹមសារស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរបស់ខេត្ត។

បន្ទាប់ពីសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តបានចូលជាធរមាន ក្រុមការងារកសាងផែនការខេត្ត ត្រូវសុំគោលការណ៍ពីគណៈអភិបាលខេត្ត រៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

មុនពេលរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ក្រុមការងារកសាងផែនការខេត្ត ត្រូវរៀបចំ ៖

- បញ្ជីឈ្មោះអ្នកត្រូវអញ្ជើញចូលរួមកិច្ចប្រជុំ
- របៀបវារៈនៃកិច្ចប្រជុំ
- ថតចម្លងសេចក្តីណែនាំ និងទម្រង់តារាងនានាដែលត្រូវបំពេញ (ទម្រង់ទី២-៥ នៃឧបសម្ព័ន្ធទី២ ក្នុងផ្នែកទី៤) សម្រាប់ចែកជូនអ្នកចូលរួមប្រជុំ
- រៀបចំឧបករណ៍សម្រាប់បង្ហាញពន្យល់ពីខ្លឹមសារនៃសេចក្តីណែនាំ និងឯកសារពាក់ព័ន្ធនានា
- កំណត់កាលបរិច្ឆេទនៃការងារដែលត្រូវធ្វើបន្ទាប់ពីកិច្ចប្រជុំផ្សព្វផ្សាយ។

បន្ទាប់ពីបានរៀបចំឯកសារខាងលើនេះរួចរាល់ហើយ ក្រុមការងារកសាងផែនការខេត្ត ត្រូវដាក់ជូនអភិបាលខេត្តពិនិត្យ និងផ្តល់យោបល់។

### ខ). ក្នុងពេលប្រជុំផ្សព្វផ្សាយ

**សមាសភាពចូលរួម**

- គណៈអភិបាលខេត្ត
- តំណាងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- ប្រធានមន្ទីរ អង្គភាពនានាជុំវិញខេត្ត
- ក្រុមការងារកសាងផែនការខេត្ត
- តំណាងទីចាត់ការនានារបស់សាលាខេត្ត
- តំណាងក្រុមប្រឹក្សាខេត្ត
- អភិបាលក្រុង ស្រុក
- តំណាងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ក្នុងខេត្ត
- តំណាងយុវជន អង្គការសង្គមស៊ីវិលនានា និងតំណាងវិស័យឯកជនក្នុងខេត្ត
- អ្នកពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។ល។

**ដំណើរការ**

អភិបាលនៃគណៈអភិបាលខេត្តដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយនេះ។ តាមការប្រគល់សិទ្ធិពីប្រធានអង្គប្រជុំ តំណាងក្រុមការងារកសាងផែនការខេត្ត ធ្វើបទបង្ហាញតាមលំដាប់លំដោយ ដូចខាងក្រោម ៖

- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- សេចក្តីណែនាំរបស់ក្រុមប្រឹក្សាខេត្តស្តីពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ប្រតិទិនការងារកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- របៀបបំពេញធាតុចូលក្នុង ៖
  - ទម្រង់ទី២ ៖ ធាតុចូលពីរដ្ឋបាលខេត្ត
  - ទម្រង់ទី៣ ៖ ធាតុចូលពីមន្ទីរ អង្គភាព
  - ទម្រង់ទី៤ ៖ ធាតុចូលពីរដ្ឋបាលក្រុង ស្រុក
  - ទម្រង់ទី៥ ៖ ធាតុចូលពីអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា

    (ទម្រង់ទី២-៥ នៃឧបសម្ព័ន្ធទី២ ក្នុងផ្នែកទី៤)

បន្ទាប់ពីការធ្វើបទបង្ហាញ ប្រធានអង្គប្រជុំបើកការពិភាក្សា និងពន្យល់ បំភ្លឺ រួចបូកសរុប ផ្តាំផ្ញើ និងបិទកិច្ចប្រជុំផ្សព្វផ្សាយ។

### គ).ការងារក្រោយកិច្ចប្រជុំផ្សព្វផ្សាយ

**ចំពោះអ្នកពាក់ព័ន្ធក្នុងការបំពេញតារាង**

បន្ទាប់ពីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត អ្នកពាក់ព័ន្ធ ត្រូវ ៖

- សម្រាប់រដ្ឋបាលខេត្ត បំពេញតារាងក្នុងទម្រង់ទី២
- សម្រាប់មន្ទីរ អង្គភាពជំនាញនានា បំពេញតារាងក្នុងទម្រង់ទី៣
- សម្រាប់រដ្ឋបាលក្រុង ស្រុក បំពេញទម្រង់ទី៤
- សម្រាប់សង្គមស៊ីវិល វិស័យឯកជន អង្គការជាតិ និងអន្តរជាតិបំពេញតារាងក្នុងទម្រង់ទី៥

**កំណត់សម្គាល់ ៖** មុនបំពេញតារាងរបស់ខ្លួន បណ្តារដ្ឋបាលក្រុង ស្រុក មន្ទីរ អង្គភាពជំនាញ សង្គមស៊ីវិល វិស័យឯកជន និងអង្គការជាតិ អន្តរជាតិ គប្បីធ្វើការវិភាគ ពិចារណាលើស្ថានភាពជាក់ស្តែង ដែលទាក់ទងនឹងវិស័យជាបេសកកម្មរបស់ខ្លួន ដើម្បីប្រាកដក្នុងខ្លួនលើបញ្ហា និងដំណោះស្រាយណាខ្លះដែលត្រូវសម្រេចចិត្តជ្រើសយក (សម្រាប់គម្រោងអាទិភាពដែលមិនទាន់មានការសន្យាគាំទ្រមូលនិធិ)។ ក្នុងការបំពេញទម្រង់ទី៣របស់មន្ទីរ អង្គភាព ពិសេសតារាងប្រតិបត្តិការសេវារដ្ឋបាល មន្ទីរ អង្គភាពនីមួយៗគប្បីពិចារណាលើ ៖

- ប្រភេទ និងចំនួនសេវារដ្ឋបាល ដែលមន្ទីរ អង្គភាពខ្លួនបានផ្តល់ជូនប្រជាពលរដ្ឋក្នុងឆ្នាំកន្លងទៅ
- ការប៉ាន់ប្រមាណអំពីប្រភេទ និងបរិមាណនៃសេវាទាំងនោះសម្រាប់ឆ្នាំបន្ទាប់
- ស្រង់ប្រភេទ និងចំនួនសេវា ចូលក្នុងតារាងប្រតិបត្តិការសេវារដ្ឋបាលនៃទម្រង់ទី៣

បន្ទាប់ពីបានបំពេញទម្រង់របស់ខ្លួនតាមការណែនាំពីក្រុមការងារកសាងផែនការខេត្តរួច រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក មន្ទីរ អង្គភាពជំនាញ សង្គមស៊ីវិល វិស័យឯកជន និងអង្គការជាតិ អន្តរជាតិសាមី ត្រូវបញ្ជូនទម្រង់ដែលបានបំពេញរួចនោះ មកក្រុមការងារកសាងផែនការខេត្តឲ្យបានទាន់ពេលវេលា។

## ២.២. ការពិនិត្យ និងចាត់អាទិភាពគម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តឡើងវិញ

### គោលបំណង

បណ្តាគម្រោង សកម្មភាពដែលបានលើកឡើងដោយរដ្ឋបាលខេត្ត មន្ទីរអង្គភាពជំនាញជុំវិញខេត្ត រដ្ឋបាលក្រុង ស្រុក និងអ្នកពាក់ព័ន្ធ ត្រូវបានយកមកពិនិត្យ ធ្វើការផ្ទៀងផ្ទាត់ និងរៀបចំតាមលំដាប់អាទិភាព។

### លទ្ធផលរំពឹងទុក

សេចក្តីព្រាងបញ្ជីគម្រោង សកម្មភាព នៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវបានរៀបចំរួច ក្នុងនោះមាន ៖

- តារាងគម្រោង សកម្មភាពអាទិភាពខ្ពស់សម្រាប់ស្វែងរកថវិកាគាំទ្រ
- តារាងគម្រោង សកម្មភាពវិនិយោគដែលមានថវិកាគាំទ្រ
- តារាងគម្រោង សកម្មភាពវិនិយោគកំពុងដំណើរការ
- តារាងគម្រោង សកម្មភាពដែលអនុវត្តដោយក្រសួង ស្ថាប័នក្នុងដែនដីខេត្ត និង
- តារាងគម្រោង សកម្មភាពវិនិយោគដែលនឹងបញ្ចប់។

### សកម្មភាពដែលត្រូវបំពេញ

### ក. ការធ្វើបច្ចុប្បន្នភាពអំពីតម្រូវការគម្រោង សកម្មភាព

បន្ទាប់ពីបានទទួលទម្រង់ទី៤ (ជាគុចូលពីរដ្ឋបាលក្រុង ស្រុក) ក្រុមការងារកសាងផែនការខេត្តត្រូវពិនិត្យបូកសរុប និងកែសម្រួលតារាង១.១.ក.តម្រូវការគម្រោង សកម្មភាពអាទិភាពរបស់ខេត្ត (ដែលបានរៀបចំក្នុងជំហានទី១ ដើម្បីរៀបចំតារាង១.១.ខ.តម្រូវការគម្រោង សកម្មភាពអាទិភាពរបស់ខេត្តដែលបានធ្វើបច្ចុប្បន្នភាពតាមលំដាប់អាទិភាព ៖

- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពឡើងវិញនូវគម្រោងអាទិភាពរបស់ខេត្ត (ដោយដកចេញគម្រោងណាដែលមិនចាំបាច់ និងបន្ថែម ឬប្តូរគម្រោងតាមជាក់ស្តែង) និងស្រង់ចូលផ្នែក"ក" នៃតារាង១.១.ខ
- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពឡើងវិញនូវគម្រោងអាទិភាពរបស់របស់ក្រុង ស្រុក (ផ្នែក "ខ" នៃតារាង ១.១.ក) ក្រុមការងារកសាងផែនការខេត្តត្រូវពិនិត្យ និងកែសម្រួល រួចស្រង់ចូលក្នុងផ្នែក "ខ" នៃតារាង១.១.ខ។

- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពឡើងវិញនូវគម្រោងអាទិភាពរបស់ឃុំ សង្កាត់នីមួយៗដើម្បីដាក់បញ្ចូលក្នុងផ្នែក"គ"នៃតារាង១.១.២។

ក្នុងការពិនិត្យ និងធ្វើបច្ចុប្បន្នភាពនេះ ក្រុមការងារកសាងផែនការខេត្ត ត្រូវស្នើសុំការបំភ្លឺពីអង្គភាពសាមីតាមការចាំបាច់។

តារាង១.១.២ ៖ តារាងតម្រូវការគម្រោង សកម្មភាពអាទិភាពទូទាំងខេត្តដែលបានធ្វើបច្ចុប្បន្នភាព

<table>
<tr><th rowspan="2">ល.រ</th><th>ឈ្មោះគម្រោង</th><th>ឆ្លើយតប</th><th>ទី</th><th colspan="2">លទ្ធផល</th><th>រយៈ</th><th colspan="2">អ្នកទទួលផល</th><th>តម្លៃប៉ាន់</th><th rowspan="2">ផ្នែក</th><th>អង្គភាព</th></tr>
<tr><th>សកម្មភាព</th><th>គោលដៅ</th><th>តាំង</th><th>បរិមាណ</th><th>ឯកតា</th><th>ពេល</th><th>សរុប</th><th>ស្រី</th><th>ស្មាន</th><th>ស្នើ</th></tr>
<tr><td colspan="12">ក ៖ តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគខេត្ត</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="12">ខ ៖ តម្រូវការគម្រោងដែលស្រុក ស្នើសុំបញ្ចូលទៅក្នុងកម្មវិធីវិនិយោគក្រុង ស្រុក</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="12">គ ៖ គម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគឃុំ សង្កាត់</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
</table>

**<u>សម្គាល់ ៖</u>**

កូឡោន "ផ្នែក" ត្រូវបញ្ជាក់ថា គម្រោងនីមួយៗនោះ ស្ថិតក្នុងក្របខ័ណ្ឌនៃផ្នែកណា ក្នុងចំណោមផ្នែកទាំង៤ ដូចខាងក្រោម ៖

- I. សំដៅលើ "ផ្នែកសេដ្ឋកិច្ច"
- II. សំដៅលើ "ផ្នែកសង្គមកិច្ច"
- III. សំដៅលើ "ផ្នែកធនធានធម្មជាតិ និងបរិស្ថាន"
- IV. សំដៅលើ "ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ"

**ខ. ការពិចារណាលើការប្រើប្រាស់ថវិកាដែលខេត្តមាន ដើម្បីគាំទ្រគម្រោង សកម្មភាព**

បន្ទាប់ពីទទួលបានព័ត៌មានអំពីលទ្ធភាពថវិកាដែលរដ្ឋបាលខេត្តមាន ក្រុមការងារកសាងផែនការខេត្ត ត្រូវពិនិត្យមើលតារាង ១.១.២ ផ្នែក "ក" ដែលបានរៀបចំខាងលើ ដើម្បីពិនិត្យមើលថា តើថវិការបស់រដ្ឋបាលខេត្តមានចំនួនប៉ុន្មាន ហើយគួរគាំទ្រការអនុវត្តគម្រោងអាទិភាពណាខ្លះ?។ ក្នុងការពិនិត្យ និងសម្រេចជាបណ្តោះអាសន្ននេះ លើការជ្រើសរើសគម្រោងអាទិភាពដើម្បីប្រើប្រាស់ថវិកាខេត្តនេះ ក្រុមការងារកសាងផែនការខេត្តត្រូវ ៖

- ជ្រើសរើសគម្រោង ឬសកម្មភាពសម្រាប់ប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ ដោយផ្អែកតាមអាទិភាពនៃសំណើគម្រោងក្នុងផ្នែកនីមួយៗ
- ជ្រើសរើសគម្រោង ឬសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារជាកាតព្វកិច្ច
- បន្ទាប់មក បន្តជ្រើសរើសគម្រោងអាទិភាពនានា សម្រាប់ប្រើប្រាស់ថវិកាខេត្ត ដែលមិនមានភ្ជាប់លក្ខខណ្ឌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្នុងការជ្រើសរើសនេះ ក្រុមការងារកសាងផែនការខេត្តត្រូវពិចារណាបន្ថែមទៀតលើ ៖
  - តុល្យភាពនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត អរូបវន្ត និងគម្រោងប្រតិបត្តិការសេវានានា
  - គម្រោងដែលឆ្លើយតបទៅទស្សនៈបរិយាប័ន្ន និងសមធម៌សង្គម ដូចជា តម្រូវការស្ត្រី កុមារ យុវជន ជនពិការ និងជនងាយរងគ្រោះ

- គម្រោងដែលឆ្លើយតបនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ
- ។ល។

- បន្ទាប់មក ក្រុមការងារកសាងផែនការខេត្ត ត្រូវរៀបចំតារាង១.១.គ (តម្រូវការគម្រោងអភិវឌ្ឍន៍សម្រាប់កម្មវិធីវិនិយោគខេត្ត) ដោយស្រង់ចេញពីផ្នែក "ក" នៃតារាង១.១.ខ និងបន្ថែមប្រភពថវិកា តាមការពិនិត្យ ពិចារណា និងសម្រេចខាងលើ។

តារាង១.១.គ ៖ តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគរដ្ឋបាលខេត្ត

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

ដោយផ្អែកតាមតារាង១.១.ខ និងតារាង១.១.គ និងលទ្ធភាពទំហំថវិកាដែលខេត្តបានដឹងសម្រាប់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ក្រុមការងារកសាងផែនការខេត្ត ត្រូវរៀបចំតារាងសង្ខេបសម្រាប់បង្ហាញនៅក្នុងវេទិកាពិគ្រោះយោបល់ តាមទម្រង់ដូចខាងក្រោម ៖

តារាងសង្ខេបនៃតម្រូវការគម្រោងវិនិយោគទូទាំងខេត្ត

| ល.រ | រដ្ឋបាល | ចំនួនគម្រោង | | | | តម្រូវការថវិកា | | | | លទ្ធភាពថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | I | II | III | IV | I | II | III | IV | | |
| ១ | រដ្ឋបាលខេត្ត | | | | | | | | | | |
| ២ | រដ្ឋបាលក្រុង | | | | | | | | | | |
| ៣ | រដ្ឋបាលស្រុក | | | | | | | | | | |
| ៤ | រដ្ឋបាលឃុំ | | | | | | | | | | |
| ៥ | រដ្ឋបាលសង្កាត់ | | | | | | | | | | |
| សរុប | | | | | | | | | | | |

**<u>សម្គាល់ ៖</u>**

- I. សំដៅលើ "ផ្នែកសេដ្ឋកិច្ច"
- II. សំដៅលើ "ផ្នែកសង្គមកិច្ច"
- III. សំដៅលើ "ផ្នែកធនធានធម្មជាតិ និងបរិស្ថាន"
- IV. សំដៅលើ "ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ"

**២.៣. វេទិកាពិគ្រោះយោបល់ពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅខេត្ត**

ការបង្កើតឡើងនូវវេទិកាពិគ្រោះយោបល់ គឺដើម្បីជាប្រយោជន៍ដល់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលទាំងរបស់ខេត្ត ក្រុង សង្កាត់ ស្រុក និងឃុំ ប្រកបដោយតម្លាភាព មានការចូលរួម មានសង្គតិភាព និងពិសេស គឺពង្រឹងការអនុវត្តនូវគោលការណ៍ទាំង៩ និងវប្បធម៌ប្រជាធិបតេយ្យក្នុងដំណើរប្រព្រឹត្តទៅនៃការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់បណ្តាថ្នាក់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។

**គោលបំណង**

ការរៀបចំវេទិកាពិគ្រោះយោបល់ពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅខេត្ត គឺដើម្បីបង្ហាញអំពីតម្រូវការអភិវឌ្ឍន៍មូលដ្ឋានទូទាំងខេត្ត និងសម្របសម្រួល បន្សីនូវតម្រូវការអភិវឌ្ឍន៍ទាំងនេះជាមួយគម្រោង និងធនធានរបស់ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីឈានដល់ការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងខេត្តប្រកបដោយប្រសិទ្ធភាព។

**លទ្ធផលរំពឹងទុក**

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន សប្បុរសជន និងអ្នកពាក់ព័ន្ធនានាបានដឹងបានយល់អំពីទស្សនៈ គោលបំណង តម្រូវការគម្រោងអភិវឌ្ឍន៍ និងលទ្ធភាពថវិកាពីគ្នាទៅវិញទៅមកដោយតម្លាភាព ហើយនឹងអាចឈានទៅដល់មានការសម្របសម្រួលគ្នា ដើម្បីឱ្យការវិនិយោគ ក៏ដូចជាការអភិវឌ្ឍនៅតាមមូលដ្ឋាននានា ប្រព្រឹត្តបានដោយរលូន មានសង្គតិភាព និងមានប្រសិទ្ធភាព។

**សមាសភាពចូលរួម**

- គណៈអភិបាលខេត្ត
- តំណាងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- ប្រធានមន្ទីរ អង្គភាពនានាជុំវិញខេត្ត
- ក្រុមការងារកសាងផែនការខេត្ត
- នាយកទីចាត់ការនានារបស់សាលាខេត្ត
- អភិបាលក្រុង ស្រុក
- តំណាងក្រុមការងារកសាងផែនការក្រុង ស្រុក
- តំណាងក្រុមប្រឹក្សាខេត្ត
- តំណាងសមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់
- អង្គការ សង្គមស៊ីវិល និងក្រុមយុវជននានាក្នុងខេត្ត
- តំណាងវិស័យឯកជនក្នុងខេត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។ល។

**ដំណើរការ**

**ក. មុនវេទិកាពិគ្រោះយោបល់**

វេទិកាពិគ្រោះយោបល់នេះជាវេទិការបស់ខេត្ត ហេតុនេះអភិបាលនៃគណៈអភិបាលខេត្តគប្បីមានការណែនាំឲ្យមានកិច្ចសហការគ្នារៀបចំ និងអនុវត្ត ៖

**ក្រុមការងារកសាងផែនការខេត្ត ៖**

- កំណត់កាលបរិច្ឆេទ និងរៀបចំរបៀបវារៈរបស់វេទិកាពិគ្រោះយោបល់ និងបញ្ជីសមាសភាពប្រតិភូត្រូវចូលរួម ដើម្បីសុំការពិនិត្យ និងណែនាំពីអភិបាលខេត្ត
- ត្រៀមរៀបចំឯកសារនានាសម្រាប់វេទិកា ៖

- តារាង ១.១.ខ. តារាងតម្រូវការគម្រោង សកម្មភាពអាទិភាពទូទាំងខេត្តដែលបានធ្វើបច្ចុប្បន្នភាព
- តារាង ១.១.គ. តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគរដ្ឋបាលខេត្ត
- តារាងសង្ខេបនៃតម្រូវការគម្រោងអភិវឌ្ឍន៍ខេត្ត

- រៀបចំសុន្ទរកថាបើកវេទិកាជូនអភិបាលខេត្ត (ប្រធានដឹកនាំវេទិកា)
- រៀបចំប្រតិទិនសម្រាប់សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគតាមក្រុង ស្រុកនីមួយៗ។

**រដ្ឋបាលខេត្ត**

- រៀបចំ និងផ្ញើលិខិតអញ្ជើញអ្នកពាក់ព័ន្ធចូលរួមវេទិកាពិគ្រោះយោបល់
- រៀបចំកន្លែងសម្រាប់វេទិកាពិគ្រោះយោបល់
- ថតចម្លងឯកសារត្រូវប្រើក្នុងវេទិកា និងផ្ញើឯកសារទាំងនោះទៅអ្នកពាក់ព័ន្ធតាមសំណូមពររបស់ក្រុមការងារកសាងផែនការខេត្ត។ល។

**ខ. អំឡុងពេលវេទិកាពិគ្រោះយោបល់**

វេទិកាពិគ្រោះយោបល់ស្តីពីកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ប្រព្រឹត្តទៅក្រោមអធិបតីភាពអភិបាលខេត្ត និងដំណើរការតាមរបៀបវារៈសំខាន់ៗដូចខាងក្រោម ៖

- ប្រកាសហេតុ ដោយអ្នកសម្របសម្រួលកម្មវិធី
- សុន្ទរកថាស្វាគមន៍ និងបើកវេទិកាពិគ្រោះយោបល់ ដោយអភិបាលខេត្ត
- តំណាងក្រុមការងារកសាងផែនការខេត្តបង្ហាញ ៖
  - តម្រូវការគម្រោង សកម្មភាពអាទិភាពទូទាំងខេត្តដែលបានធ្វើបច្ចុប្បន្នភាព
  - តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគខេត្ត
  - តារាងសង្ខេបនៃតម្រូវការគម្រោងវិនិយោគទូទាំងខេត្ត
- តំណាងមន្ទីរ អង្គភាពជំនាញនីមួយៗបង្ហាញអំពីគម្រោងអភិវឌ្ឍន៍ដែលមានថវិកា និងទីតាំងគម្រោងនីមួយៗសម្រាប់អនុវត្តក្នុងឆ្នាំបន្ទាប់ និងថ្នាក់រដ្ឋបាលដែលត្រូវសហការអនុវត្ត
- តំណាងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនីមួយៗបង្ហាញអំពី ៖
  - គម្រោងអភិវឌ្ឍន៍ដែលមានថវិកា ទីតាំងគម្រោងនីមួយៗ និងថ្នាក់រដ្ឋបាលដែលត្រូវសហការអនុវត្តក្នុងឆ្នាំបន្ទាប់
  - លទ្ធភាពថវិកា (ក្នុងករណីដែលមិនទាន់មានគម្រោងច្បាស់លាស់)
- ការពិភាក្សា និងបន្សីគម្រោងរវាងគម្រោងវិនិយោគខេត្ត ជាមួយគម្រោងរបស់ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា
- ក្រុមការងារកសាងផែនការខេត្តបង្ហាញអំពីកាលបរិច្ឆេទស្តីពីការធ្វើសិក្ខាសាលាសមាហរណកម្មនៅតាមបណ្តាស្រុក ក្រុង
- អធិបតីនៃវេទិកាបូកសរុប និងបិទកម្មវិធី។

ជាមួយគ្នានេះ ក្រុមការងារកសាងផែនការខេត្ត និងឬតំណាងរដ្ឋបាលខេត្ត ក្រុង ស្រុក ដែលបានចូលរួមក្នុងវេទិកាត្រូវព្យាយាមស្តាប់ និងកត់ត្រាព័ត៌មានសំខាន់ៗ ពិសេសពាក់ព័ន្ធនឹងឈ្មោះមន្ទីរ អង្គភាពដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនីមួយៗ ដែលនឹងអនុវត្តគម្រោងក្នុងដែនដីរបស់ខ្លួន ព្រមទាំងឈ្មោះគម្រោង និងទីតាំងគម្រោង ដែលត្រូវអនុវត្តក្នុងដែនដីរបស់ខ្លួន។

**កំណត់សម្គាល់** ៖ ករណីមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ និងឬពីអ្នកពាក់ព័ន្ធនានាលើគម្រោង សកម្មភាពវិនិយោគរបស់ខេត្ត រដ្ឋបាលខេត្តអាចរៀបចំចុះអនុស្សរណៈយោគយល់គ្នារវាងរដ្ឋបាលខេត្តជាមួយដៃគូអភិវឌ្ឍន៍ អ្នកពាក់ព័ន្ធសាមីនីមួយៗនោះ។

**គ. ក្រោយវេទិកាពិគ្រោះយោបល់**

**សម្រាប់ក្រុមការងារកសាងផែនការខេត្ត**

ដោយផ្អែកលើលទ្ធផលដែលទទួលបានពីវេទិកាពិគ្រោះយោបល់ និងទម្រង់ទី២ ទម្រង់ទី៣ ទម្រង់ទី៤ និងទម្រង់ទី៥ ដែលបានទទួលពីអ្នកពាក់ព័ន្ធនានា ក្រុមការងារកសាងផែនការខេត្តត្រូវរៀបចំ ៖

- តារាង២.១ ៖ សង្ខេបប្រភពមូលនិធិ
- តារាង២.២ ៖ គម្រោង សកម្មភាពកំពុងដំណើរការ
- តារាង២.៣ ៖ គម្រោង សកម្មភាពខេត្តដែលមានថវិកាគាំទ្រ
- តារាង២.៤ ៖ គម្រោង សកម្មភាពខេត្តដែលមិនទាន់មានថវិកាគាំទ្រ (យកចេញពីតារាង១.១.គ)
- តារាង២.៥ ៖ កម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់រដ្ឋបាលខេត្ត និងរបស់មន្ទីរ អង្គភាព
- តារាង២.៦ ៖ លិខិតបទដ្ឋាននានារបស់រដ្ឋបាលខេត្តដែលនឹងដាក់ឲ្យប្រើប្រាស់
- តារាង២.៧ ៖ គម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័ន កំពុងអនុវត្តក្នុងដែនដីខេត្ត

(ទម្រង់តារាងខាងលើ មាននៅក្នុងផ្នែកទី២នៃសេចក្តីណែនាំបច្ចេកទេសនេះ)

**សម្រាប់ក្រុមការងារកសាងផែនការក្រុង ស្រុក**

ដោយផ្អែកលើលទ្ធផលដែលទទួលបានពីវេទិកានៅថ្នាក់ខេត្ត អភិបាលក្រុង ស្រុកអាចកំណត់បាននូវឈ្មោះស្ថាប័ន ឈ្មោះគម្រោង និងទីតាំងគម្រោង ដែលនឹងអនុវត្តគម្រោងនៅក្នុងដែនដីក្រុង ស្រុករបស់ខ្លួន។ អភិបាលក្រុង ស្រុកត្រូវណែនាំឲ្យក្រុមការងារកសាងផែនការទាក់ទងជាមួយស្ថាប័ននីមួយៗនោះ ដើម្បីសួរបញ្ជាក់ឡើងវិញឲ្យប្រាកដថា តើស្ថាប័ននីមួយៗនោះមានគម្រោងអ្វីខ្លះ? ទីតាំងពិតប្រាកដនៅកន្លែងណា? តើរដ្ឋបាលថ្នាក់ណាដែលស្ថាប័ននោះនឹងសហការអនុវត្តគម្រោងនោះ? ប្រសិនបើស្ថាប័ននោះគ្រោងនឹងសហការជាមួយរដ្ឋបាលក្រុង ស្រុក ក្រុមការងារកសាងផែនការក្រុង ស្រុកត្រូវស្រង់គម្រោងនោះដាក់បញ្ចូលក្នុងតារាង១.១.គ.របស់ខ្លួន ប៉ុន្តែប្រសិនបើស្ថាប័ននោះគ្រោងនឹងសហការអនុវត្តជាមួយរដ្ឋបាលឃុំ សង្កាត់ ក្រុមការងារកសាងផែនការក្រុង ស្រុក ត្រូវស្រង់គម្រោងទាំងនោះបញ្ជូនទៅឲ្យ គ.ផ.ថ នៃឃុំ សង្កាត់សាមី ដើម្បីដាក់បញ្ចូលទៅក្នុងតារាង១.១.គ របស់ឃុំ សង្កាត់នោះ។

**សម្រាប់មន្ទីរ អង្គភាព ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា**

មន្ទីរ អង្គភាព ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដែលបានបង្ហាញគម្រោងរបស់ខ្លួននៅក្នុងវេទិកាពិគ្រោះយោបល់នៅថ្នាក់ខេត្ត ត្រូវត្រៀមរៀបចំសម្រាប់ការចូលរួមគាំទ្រដល់គម្រោង សកម្មភាព ដែលស្នើឡើងនៅក្នុងសិក្ខាសាលាសមាហរណកម្មនៅតាមបណ្តាស្រុក ក្រុង តាមកាលបរិច្ឆេទ និងការអញ្ជើញចូលរួម។

**២.៤. ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅតាមបណ្តាស្រុក ក្រុង**

ការគ្រប់គ្រង និងដឹកនាំសិក្ខាសាលាសមាហរណកម្មនៅក្រុង ស្រុក ជាភារកិច្ចរបស់រដ្ឋបាលក្រុង ស្រុកសាមី។ តំណាងរដ្ឋបាលខេត្ត មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានានៅថ្នាក់ខេត្ត ដែលត្រូវចូលរួមតាមការអញ្ជើញ គឺជាអ្នកផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ឬផ្នែកបច្ចេកទេស ឬផ្នែកស្មារតីដល់រដ្ឋបាលក្រុង ស្រុក សង្កាត់ ឃុំ ភូមិ សហគមន៍ និងប្រជាជនផងដែរ ទោះបីជាមាន ឬគ្មានគម្រោងគាំទ្រក៏ដោយ។

រដ្ឋបាលខេត្ត មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានានៅថ្នាក់ខេត្ត គួរចាត់តាំងតំណាងរបស់ខ្លួន ដែលមានសិទ្ធិសម្រេច និងចុះកិច្ចព្រមព្រៀងបណ្តោះអាសន្នជាមួយរដ្ឋបាលក្រុង ស្រុក ឬឃុំ សង្កាត់ តាមការចាំបាច់។

**២.៥. ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**

បន្ទាប់ពីរៀបចំបណ្តាតារាងខាងលើ (សកម្មភាព ២.៣.) ក្រុមការងារកសាងផែនការខេត្ត ត្រូវពិនិត្យ និងកែសម្រួលបញ្ចប់នូវ ៖

- តារាង២.១ ៖ សង្ខេបប្រភពមូលនិធិ

- តារាង២.២ ៖ គម្រោង សកម្មភាពកំពុងដំណើរការ
- តារាង២.៣ ៖ គម្រោង សកម្មភាពខេត្តដែលមានថវិកាគាំទ្រ
- តារាង២.៤ ៖ គម្រោង សកម្មភាពខេត្តដែលមិនទាន់ថវិកាគាំទ្រ
- តារាង២.៥ ៖ កម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់រដ្ឋបាលខេត្ត និងមន្ទីរ អង្គភាព
- តារាង២.៦ ៖ លិខិតបទដ្ឋាននានារបស់រដ្ឋបាលខេត្តដែលនឹងដាក់ឲ្យប្រើប្រាស់
- តារាង២.៧ ៖ គម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័នអនុវត្តក្នុងដែនដីខេត្ត

បន្ទាប់កែសម្រួលបញ្ចប់តារាងខាងលើហើយ ក្រុមការងារកសាងផែនការខេត្តត្រូវរៀបចំសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដោយផ្អែកតាមមាតិកានៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដោយត្រូវសរសេរបរិយាយ ស្របតាមសេចក្តីពន្យល់ដែលមានក្នុងផ្នែកទី២នៃសេចក្តីណែនាំនេះ។

## ២.៦. ការរៀបចំការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល

ដើម្បីឲ្យការអនុវត្តការតាមដាន និងវាយតម្លៃការអនុវត្តគម្រោង សកម្មភាពក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តមានប្រសិទ្ធភាព និងមានប្រយោជន៍នោះ អភិបាលខេត្ត ដោយបានការឯកភាពពីក្រុមប្រឹក្សាខេត្តណែនាំឲ្យក្រុមការងារកសាងផែនការខេត្ត រៀបចំគោលការណ៍ និងនីតិវិធីប្រតិបត្តិការ ដែលមាន ៖

៣.១. ក្របខ័ណ្ឌតាមដាន វាយតម្លៃ ( យុទ្ធសាស្រ្ត វិធីសាស្រ្ត ផែនការសកម្មភាព )

៣.២. ការបែងចែកភារកិច្ចដល់អ្នកពាក់ព័ន្ធក្នុងការតាមដាននិងវាយតម្លៃ ( យន្តការ ភារកិច្ច )

### តារាងតាមដានការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

| ល.រ. | ឈ្មោះគម្រោង | គ្រោង/ជាក់ស្តែង | លទ្ធផល | | រយៈពេលអនុវត្ត | តម្លៃគម្រោង | អង្គភាពអនុវត្ត | % នៃការសម្រេច | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | | |
| **គម្រោងរបស់រដ្ឋបាលខេត្ត** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **គម្រោងរបស់មន្ទីរ អង្គភាព** | | | | | | | | | |
| **មន្ទីរ អង្គភាព**......... | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការអនុវត្តកម្មវិធីប្រតិបត្តិការសេវាកម្មរបស់រដ្ឋបាលខេត្ត** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការអនុវត្តកម្មវិធីប្រតិបត្តិការសេវាកម្មរបស់មន្ទីរ អង្គភាព** | | | | | | | | | |
| **មន្ទីរ អង្គភាព**... | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលខេត្ត** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |

គម្រោងដែលត្រូវស្រង់បញ្ចូលក្នុងតារាងខាងលើ គឺ ៖

- គម្រោងដែលមានការថវិកាគាំទ្រ និង
- គម្រោងកំពុងដំណើរការ។

## ២.៧. ការពិនិត្យ និងផ្តល់យោបល់

បន្ទាប់ពីរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលហើយ ក្រុមការងារកសាងផែនការខេត្តត្រូវ ៖

- ដាក់សេចក្តីព្រាងសៀវភៅនេះ ជូនទៅគណៈអភិបាលខេត្ត ដើម្បីពិនិត្យ និងផ្តល់យោបល់
- ពិនិត្យ និងកែសម្រួលសេចក្តីព្រាងសៀវភៅ តាមមតិយោបល់ និងអនុសាសន៍របស់គណៈអភិបាល
- ដាក់សេចក្តីព្រាងសៀវភៅនេះ ជូនទៅគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត ដើម្បីពិនិត្យ និងផ្តល់យោបល់
- ពិនិត្យ និងកែសម្រួលសេចក្តីព្រាងសៀវភៅតាមមតិយោបល់ និងអនុសាសន៍របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត
- ដាក់សេចក្តីព្រាងចុងក្រោយជូនអភិបាលខេត្ត ដើម្បីបញ្ជូនទៅក្រុមប្រឹក្សាខេត្ត។

## ជំហានទី៣

## ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**គោលបំណង**

គោលបំណងនៃជំហាននេះ គឺដើម្បីក្រុមប្រឹក្សាខេត្តពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្របតាមខ្លឹមសារនៃមាត្រា៣៦ និង៣៧នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**លទ្ធផលរំពឹងទុក**

សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត បានចូលជាធរមាន និងមានតម្លៃគតិយុត្តក្នុងការប្រើប្រាស់។

**ដំណើរការ**

សកម្មភាពសំខាន់ក្នុងជំហានទី៣នេះ រួមមាន ៖

៣.១. កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

៣.២. ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

### ៣.១. កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

បន្ទាប់ពីទទួលបានសៀវភៅព្រាងចុងក្រោយនៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុមប្រឹក្សាខេត្តរៀបចំកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាខ្លួន ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តនេះ។

ដើម្បីជានាភាពរលូន និងជោគជ័យក្នុងកិច្ចប្រជុំពិនិត្យ និងអនុម័តសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ការងារដែលត្រូវធ្វើមានដូចខាងក្រោម ៖

**មុនកិច្ចប្រជុំ**

ក្រុមការងារកសាងផែនការខេត្ត ដោយមានជំនួយពីនាយករដ្ឋបាលសាលាខេត្ត ត្រូវរៀបចំ ៖

- របៀបវារៈកិច្ចប្រជុំជូនប្រធានក្រុមប្រឹក្សាខេត្តពិនិត្យ និងណែនាំ
- រៀបចំសេចក្តីថ្លែងហេតុជូនអភិបាលខេត្ត ដោយមានសង្ខេបខ្លឹមសារនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- ថតចម្លងសេចក្តីថ្លែងហេតុ និងសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ទុកសម្រាប់ចែកជូនអ្នកចូលរួមប្រជុំ
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តទៅអ្នកពាក់ព័ន្ធឲ្យបានយ៉ាងតិច៣ថ្ងៃមុនកិច្ចប្រជុំ (ដោយនាយករដ្ឋបាលនៃសាលាខេត្ត) និង
- រៀបចំកិច្ចការចាំបាច់ផ្សេងៗទៀតតាមការណែនាំរបស់អភិបាលខេត្ត ឬប្រធានក្រុមប្រឹក្សាខេត្ត។

**ក្នុងពេលប្រជុំ**

**សមាសភាពចូលរួម**

- សមាជិកក្រុមប្រឹក្សាខេត្ត
- គណៈអភិបាលខេត្ត
- នាយករដ្ឋបាលសាលាខេត្ត
- ក្រុមការងារកសាងផែនការខេត្ត
- ក្រុមលេខាកត់ត្រារបស់ក្រុមប្រឹក្សាខេត្ត
- តំណាងមន្ទីរ អង្គភាពនិងអ្នកពាក់ព័ន្ធ តាមការចាំបាច់។

**ដំណើរការកិច្ចប្រជុំ**

សកម្មភាពក្នុងកិច្ចប្រជុំក្រុមប្រឹក្សាខេត្តនេះ រួមមាន ៖

- ប្រធានក្រុមប្រឹក្សាខេត្តបើកអង្គប្រជុំ និងដឹកនាំប្រជុំ
- អភិបាលខេត្ត អានសេចក្តីថ្លែងហេតុជូនអង្គប្រជុំ
- តាមការចាត់តាំងពីអភិបាលខេត្ត និងមានការឯកភាពពីប្រធានអង្គប្រជុំ តំណាងក្រុមការងារកសាងផែនការខេត្តធ្វើបទបង្ហាញពីខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- សមាជិកក្រុមប្រឹក្សាខេត្តពិនិត្យ ពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត (ឧបសម្ព័ន្ធទី៥ ក្នុងផ្នែកទី៤)
- ការអនុម័តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត តាមគោលការណ៍ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខេត្ត
- ប្រកាសបិទសម័យប្រជុំ។

**ក្រោយកិច្ចប្រជុំ**

បន្ទាប់ពីកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត ក្រុមការងារកសាងផែនការខេត្តត្រូវ ៖

- ធ្វើការកែតម្រូវបណ្តាចំណុចក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត តាមការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត
- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត
- យកសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដែលបានកែតម្រូវចុងក្រោយ និងសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តជូនអភិបាលខេត្តពិនិត្យ
- អភិបាលខេត្តពិនិត្យរួចហើយ យកសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តដោយមានអមជាមួយនូវសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដែលបានកែតម្រូវចុងក្រោយជូនប្រធានក្រុមប្រឹក្សាខេត្តពិនិត្យ និងចុះហត្ថលេខា។

### ៣.២. ការបោះពុម្ព និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**ការបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**

អភិបាល នៃគណៈអភិបាលខេត្ត ពិនិត្យ និងណែនាំការបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

**ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត**

តាមការឯកភាពយោបល់រវាងក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវបានតម្កល់នៅសាលាខេត្ត(មណ្ឌលព័ត៌មាន) មន្ទីរផែនការខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត និងផ្ញើជូនក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នអ្នកពាក់ព័ន្ធតាមការចាំបាច់។

ជាមួយនឹងការផ្សព្វផ្សាយតាមការចែកសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត អភិបាលខេត្ត គប្បីណែនាំឲ្យមានការផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដូចជាផ្សព្វផ្សាយក្នុងកិច្ចប្រជុំនានាក្នុងវេទិកាសាធារណៈ តាមសារព័ត៌មាន វិទ្យុ និងតាមមធ្យោបាយផ្សេងៗទៀតដែលអាចធ្វើបាន។ល។ លើសពីនេះទៀត អភិបាលខេត្តត្រូវណែនាំឲ្យក្រុមការងារកសាងផែនការខេត្តរៀបចំបញ្ជីគម្រោង (គម្រោងដែលមានការសន្យាគាំទ្រ និងគម្រោងកំពុងអនុវត្ត) នៅតាមឃុំ សង្កាត់នីមួយៗដោយឡែកៗពីគ្នា ដើម្បីផ្ញើទៅឲ្យឃុំ សង្កាត់សាមីសម្រាប់ផ្សព្វផ្សាយជូនប្រជាពលរដ្ឋ។

# ផ្នែកទី៤

# ឧបសម្ព័ន្ធសម្រាប់ជាជំនួយស្មារតី

# នៅពេលរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្ត...........** ...........ថ្ងៃទី...........ខែ...........ឆ្នាំ...........

លេខ ៖---------------

**សេចក្តីណែនាំ**
**ស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល.....**

## (សេចក្តីណែនាំគប្បីសរសេរជា៦ កថាខណ្ឌ)

កថាខណ្ឌទី១ ៖ ជាសេចក្តីផ្តើមនៃសេចក្តីណែនាំ ដោយសរសេររៀបរាប់ពីចំណុចសំខាន់ៗរបស់ឯកសារគតិយុត្តដែលពាក់ព័ន្ធនឹងតួនាទីរបស់ក្រុមប្រឹក្សាខេត្តក្នុងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

កថាខណ្ឌទី២ ៖ សរសេររៀបរាប់សង្ខេបពីស្ថានភាពទូទៅក្នុងខេត្ត (សេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រហូតដល់រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ)។ ការសរសេររៀបរាប់នេះ គប្បីមានរំលេចទាំងភាពល្អប្រសើរ និងភាពមិនទាន់ល្អប្រសើរ។ មូលដ្ឋានព័ត៌មានសម្រាប់សរសេរ គឺស្រង់ចេញពីឯកសារពិន្ទុតាម វិស័យរបស់ខេត្ត ដែលមន្ទីរផែនការខេត្តចងក្រងចេញពីទិន្នន័យមូលដ្ឋានឃុំ សង្កាត់។

កថាខណ្ឌទី៣ ៖ សរសេរពីគោលបំណង និងទិសដៅនៃការអភិវឌ្ឍខេត្តនៅឆ្នាំខាងមុខ។ ក្នុងវាក្យខណ្ឌនេះ ត្រូវបង្ហាញពីវិស័យណាខ្លះដែលខេត្តមានគំនិតចាត់ទុកជាអាទិភាព ដែលចង់ឲ្យអ្នកពាក់ព័ន្ធពិចារណា និងរៀបចំគម្រោង សកម្មភាពក្នុងវិស័យខ្លួន ដើម្បីឆ្លើយតប និងដោះស្រាយ។

កថាខណ្ឌទី៤ ៖ សរសេរពីតួនាទីរបស់អ្នកពាក់ព័ន្ធ ដែលត្រូវប្រតិបត្តិក្នុងដំណើរប្រព្រឹត្តទៅនៅពេលរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

កថាខណ្ឌទី៥ ៖ សរសេរអំពីប្រតិទិននៃការអនុវត្តតាមជំហាននីមួយៗក្នុងដំណោះរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត។

កថាខណ្ឌទី៦ ៖ សរសេរមានន័យដែលមានលក្ខណៈបញ្ជា ដូចជា ទទួលបានសេចក្តីណែនាំនេះ ក្រុមការងារកសាងផែនការខេត្ត ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា ត្រូវចាត់ចែងផ្សព្វផ្សាយ និងអនុវត្តឲ្យមានប្រសិទ្ធភាព។

ហត្ថលេខានិងត្រា
ប្រធានក្រុមប្រឹក្សាខេត្ត

ចម្លងជូន ៖
- ក
- ខ

**ឧបសម្ព័ន្ធទី២ ÷ ទម្រង់ធាតុចូល**

## ទម្រង់ទី១
## ធាតុចូលអំពីការវិភាគស្ថានភាព និងតម្រូវការអភិវឌ្ឍន៍

### ក). ការវិភាគស្ថានភាព

- ចំណុចខ្លាំង
- ចំណុចខ្សោយ/បញ្ហាប្រឈម
- បញ្ហាអាទិភាពសំខាន់ៗដែលត្រូវដោះស្រាយចំពោះមុខ។

### ខ). តម្រូវការគម្រោង សកម្មភាពជាអាទិភាព

| ល.រ | ឈ្មោះគម្រោង | គោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| **ក. គម្រោងដែលរដ្ឋបាល ឬអង្គភាពសាមីមានលទ្ធភាពអនុវត្ត** | | | | | | | | | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤. ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| **ខ. គម្រោងដែលរដ្ឋបាល ឬអង្គភាពស្នើសុំបញ្ចូលទៅក្នុងកម្មវិធីវិនិយោគខេត្ត** | | | | | | | | | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤. ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| **គ. គម្រោងសម្រាប់កម្មវិធីវិនិយោគឃុំ សង្កាត់** | | | | | | | | | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| ……… | | | | | | | | | | |
| | | | | | | | | | | |

ថ្ងៃទី.............. ខែ............. ឆ្នាំ២០..........
អ្នករៀបចំ

បានឃើញ និងឯកភាព
ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
**ប្រធានអង្គភាព**

# ទម្រង់ទី២

## ធាតុចូលពីរដ្ឋបាលខេត្ត ឆ្នាំ...........

| លរ. | ឈ្មោះគម្រោង | ផ្នែក | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន | អ្នកទទួលផល | | អ្នកគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | (លានរៀល) | សរុប | ស្រី | |
| **គម្រោងប្រើប្រាស់ថវិកាខេត្ត** | | | | | | | | | |
| ក. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| គ. មិនបានអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោងខេត្តដែលមានថវិកាគាំទ្រ** | | | | | | | | | |
| ឃ. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ង. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ច. មិនបានអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោងដែលបានអនុម័ត ប៉ុន្តែមិនមានការសន្យាគាំទ្រ និងក្រៅសំណើសុំការគាំទ្រ** | | | | | | | | | |
| ឆ. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ជ. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

តារាងកម្មវិធីប្រតិបត្តិកាសេវារដ្ឋបាលរបស់រដ្ឋបាលខេត្ត ឆ្នាំ.....

| លរ | ប្រភេទសេវារដ្ឋបាល | លទ្ធផលគ្រោង | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|
| | | បរិមាណ | ឯកតា | | |
| | | | | | |
| | | | | | |
| | | | | | |

តារាងលិខិតបទដ្ឋាននានារបស់រដ្ឋបាលខេត្តដែលត្រូវរៀបចំ និងដាក់ឲ្យប្រើប្រាស់ ឆ្នាំ.....

| លរ | ប្រភេទលិខិតបទដ្ឋាន | លទ្ធផលគ្រោង | | ផ្សេងៗ |
|---|---|---|---|---|
| | | បរិមាណ | ឯកតា | |
| | | | | |
| | | | | |
| | | | | |

ថ្ងៃទី.................. ខែ............. ឆ្នាំ២០..........
អ្នករៀបចំតារាង

បានឃើញ និងឯកភាព
ថ្ងៃទី.................. ខែ............. ឆ្នាំ២០..........
នាយករដ្ឋបាល

## ទម្រង់ទី៣

### ធាតុចូលពីមន្ទីរ អង្គភាព........... ឆ្នាំ..........

| ល.រ. | ឈ្មោះគម្រោង | ផ្នែក | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន (លានរៀល) | អ្នកទទួលផល | | ប្រភពមូលនិធិ |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| ក. គម្រោងបានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ. គម្រោងកំពុងដំណើរការ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| គ. គម្រោងមានការសន្យាគាំទ្រ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោងរបស់ក្រសួង ស្ថាប័នខ្សែបណ្តាយរបស់មន្ទីរ អង្គភាពសាមី** | | | | | | | | | |
| គ. គម្រោងបានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ង. គម្រោងកំពុងដំណើរការ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

តារាងកម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់មន្ទីរ អង្គភាព

| ល.រ | ប្រភេទសេវារដ្ឋបាល | លទ្ធផលគ្រោង | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|
| | | បរិមាណ | ឯកតា | | |
| | | | | | |
| | | | | | |
| | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
ប្រធានមន្ទីរ អង្គភាព....

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
អ្នករៀបចំតារាង

## ទម្រង់ទី៤

### ធាតុចូលពីរដ្ឋបាលក្រុង ស្រុក........... ឆ្នាំ..........

តារាងតម្រូវការគម្រោង សកម្មភាពអាទិភាពរបស់រដ្ឋបាលក្រុង ស្រុក........

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ក ៖ តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគក្រុង  ស្រុក | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ ៖ តម្រូវការគម្រោងដែលស្រុក ស្នើសុំបញ្ចូលទៅក្នុងកម្មវិធីវិនិយោគខេត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| គ ៖ គម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគឃុំ សង្កាត់ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

បានឃើញ និងឯកភាព

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

អភិបាលក្រុង ស្រុក ......

អ្នករៀបចំ

## ទម្រង់ទី៥

### ធាតុចូលអង្គការសង្គមស៊ីវិល វិស័យឯកជន........... ឆ្នាំ..........

| ល.រ. | ឈ្មោះគម្រោង | ផ្នែក | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន (លានរៀល) | អ្នកទទួលផល | | ប្រភពមូលនិធិ |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| ក. គម្រោងបានអនុវត្តបញ្ចប់ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ. គម្រោងកំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| គ. គម្រោងដែលមានថវិកាគាំទ្រ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

បានឃើញ និងឯកភាព

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

ប្រធាន.......

អ្នករៀបចំតារាង

# ទម្រង់ទី៦
# គម្រោងវិនិយោគរបស់រដ្ឋបាលខេត្ត
# ដែលត្រូវអនុវត្តក្នុងដែនដីឃុំ សង្កាត់................. សម្រាប់ឆ្នាំ...........

| ល.រ | ឈ្មោះគម្រោង | ទីតាំង | ប្រភពថវិកា | ស្ថានភាពគម្រោង | |
|---|---|---|---|---|---|
| | | | | កំពុងដំណើរការ | មានថវិកាគាំទ្រ |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

អ្នករៀបចំតារាង

បានឃើញ និងឯកភាព
ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
អភិបាលខេត្ត

**ឧបសម្ព័ន្ធទី៣**

## វិធីសាស្ត្រចាត់អាទិភាព

ការចាត់អាទិភាពគម្រោង សកម្មភាព មានវិធីសាស្ត្របួន (០៤) ដែលគេនិយមប្រើ គឺ ១).វិធីសាស្ត្រផ្តល់ពិន្ទុផ្អែកលើលក្ខណៈវិនិច្ឆ័យ ២).វិធីសាស្ត្រផ្ទឹមផ្ទង ៣).វិធីសាស្ត្រជ្រើសរើសដោយដាក់ពិន្ទុ តាមជម្រើស និង ៤).វិធីសាស្ត្រ Pay off matrix។ ក្នុងចំណោមវិធីសាស្ត្រទាំងនេះ វិធីសាស្ត្រផ្តល់ពិន្ទុ ផ្អែកតាមលក្ខណៈវិនិច្ឆ័យ គឺជាវិធីសាស្ត្រសាមញ្ញ។

ក្នុងការអនុវត្តវិធីសាស្ត្រនេះ ក្រុមការងារកសាងផែនការ ឬអ្នកពាក់ព័ន្ធនានាអាចពិចារណា និងអនុវត្តតាមចំណុចនីមួយៗដូចខាងក្រោម ៖

- ស្រង់ជម្រើសនានា ដែលត្រូវចាត់អាទិភាពចូលក្នុងតារាង
- ពិភាក្សា និងកំណត់លក្ខណៈវិនិច្ឆ័យនានា។ ជាទូទៅលក្ខណៈវិនិច្ឆ័យមានការប្រែប្រួលទៅតាមលក្ខណៈនៃជម្រើស ឬបញ្ហា ឬដំណោះស្រាយ។ ជាទូទៅលក្ខណៈវិនិច្ឆ័យដែលចាំបាច់ គួរតែមាននៅគ្រប់ជម្រើស ឬដំណោះស្រាយ គឺការឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ក្រុមងាយរងគ្រោះដាក់លាក់ណាមួយ និងភាពសមធម៌។
- ពិនិត្យជម្រើសនីមួយៗម្តងមួយៗ ដោយធៀបជាមួយលក្ខណៈវិនិច្ឆ័យដែលបានកំណត់។ ពិន្ទុដែលទទួលបានពីការប្រៀបធៀបត្រូវកំណត់ជាលេខ។ ពិន្ទុទាបជាងគេ០១ ហើយពិន្ទុខ្ពស់ជាងគេ គឺស្មើនឹងចំនួនជម្រើសសរុប ។

**ឧទាហរណ៍ ៖** អំពីតារាងនៃវិធីផ្តល់ពិន្ទុផ្អែកលើលក្ខណៈវិនិច្ឆ័យ

| ជម្រើស | លក្ខណៈវិនិច្ឆ័យ | | | | | សរុបពិន្ទុ |
|---|---|---|---|---|---|---|
| | ការឆ្លើយតបតម្រូវការ | ការនិយមចូលចិត្ត | ការថែទាំ | សមធម៌ | ប្រសិទ្ធភាពតម្លៃ | |
| គម្រោង "ក" | 2 | 3 | 5 | 1 | 5 | 16 |
| គម្រោង "ខ" | 4 | 5 | 4 | 3 | 4 | 20 |
| គម្រោង "គ" | 3 | 3 | 3 | 2 | 3 | 14 |
| គម្រោង "ឃ" | 5 | 1 | 2 | 4 | 1 | 13 |
| គម្រោង "ង" | 1 | 1 | 2 | 1 | 1 | 6 |

តាមរយៈឧបករណ៍នេះ ក្រុមការងារបានកំណត់យកគម្រោងចំនួន០៥ និងលក្ខណៈវិនិច្ឆ័យចំនួន០៥ មកធ្វើជាសមាសធាតុសម្រាប់រៀបលំដាប់ថ្នាក់អាទិភាពនៃគម្រោង។ តាមការផ្តល់ពិន្ទុក្នុងតារាងខាងលើ យើងឃើញថា ៖

| **ជំរើស** | **អាទិភាព** |
|---|---|
| គម្រោង "ខ" | ១ |
| គម្រោង "ក" | ២ |
| គម្រោង "គ" | ៣ |
| គម្រោង "ឃ" | ៤ |
| គម្រោង "ង" | ៥ |

**ឧបសម្ព័ន្ធទី៤**

## វិធីសាស្ត្រវិភាគស្ថានភាព
## វិធីសាស្ត្រវិភាគឯកសារព័ត៌មានស្ថានភាព និងឯកសារពិន្ទុវិស័យ

ក្នុងការវិភាគស្ថានភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីកំណត់ពីតម្រូវការ គម្រោងអាទិភាព ក្រុមការងារកសាងផែនការខេត្តត្រូវធ្វើការវិភាគ និងកំណត់អំពីចំណុចខ្លាំង ចំណុចខ្សោយរបស់វិស័យនីមួយៗ ដោយផ្អែកលើទិន្នន័យភូមិ ទិន្នន័យឃុំ សង្កាត់ ឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងទិន្នន័យឬព័ត៌មាន (ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ពិន្ទុវិស័យ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផែនទីសេវាសង្គម...) និងឧបករណ៍វិភាគផ្សេងៗ ដើម្បីកំណត់អំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយនានា។

ក្នុងការវិភាគដោយប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព ពិន្ទុវិស័យ ក្រុមការងារកសាងផែនការ ត្រូវ ៖

- ពិនិត្យមើលទិន្នន័យ ឬព័ត៌មានដែលមានក្នុងឯកសារព័ត៌មានស្ថានភាពម្តងមួយចំណុចៗ
- ផ្អែកលើទិន្នន័យ និងព័ត៌មាននីមួយៗ តើអ្វីជាបញ្ហាដែលមានការប្រឈមខ្លាំងដល់បុរស ស្ត្រី ជនពិការ កុមារ និងក្រុមជនងាយរងគ្រោះជាក់លាក់ណាមួយ ដែលត្រូវធ្វើការដោះស្រាយ ឬអន្តរាគមន៍?
- បន្ទាប់ពីកំណត់បញ្ហារួច ត្រូវធ្វើការពិភាក្សាដើម្បីកំណត់ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយ
- ស្រង់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយចូលក្នុង តារាងដូចខាងក្រោម។

**បញ្ហា តម្រូវការ និងដំណោះស្រាយ**

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ក្រៅពីវិធីសាស្ត្រខាងលើនេះ ក្រុមការងារកសាងផែនការ ឬ គ.ផ.ថ អាចប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រផ្សេងៗទៀតដូចជា ដើមឈើបញ្ហា ការវិភាគការប្រែប្រួលអាកាសធាតុ ឬ SWOT តាមការចាំបាច់។

**ឧបសម្ព័ន្ធទី៥**

## ចំណុចគន្លឹះសម្រាប់ក្រុមប្រឹក្សា
## ពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល

ជាជំនួយស្មារតី ក្នុងការពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ក្រុមប្រឹក្សាគប្បីយកចិត្តទុកដាក់លើចំណុចគន្លឹះនានា ដូចខាងក្រោម ៖

1. តើការរៀបចំសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្របតាមមាតិកាដែលបានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសដែរឬទេ ?
2. តើដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល អនុវត្តតាមជំហាននានាដូចបានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសឬទេ ?
3. តើមានការវិភាគស្ថានភាពជាក់ស្តែងដែរឬទេ ?
4. តើទិន្នន័យ និងព័ត៌មានដែលបានយកមកប្រើ គឺជាទិន្នន័យ និងព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពឬទេ ?
5. តើការវិភាគស្ថានភាព បានផ្តោតលើបញ្ហារបស់ស្ត្រី បុរស កុមារ ជនពិការ យុវជន ឬក្រុមជនងាយរងគ្រោះជាក់លាក់ឬទេ ?
6. តើការវិភាគស្ថានភាព បានផ្តោតលើបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុឬទេ ?
7. តើបានកំណត់អំពីបញ្ហាប្រឈម និងដំណោះស្រាយសមស្រប សម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ពិសេស ស្ត្រី បុរស កុមារ និងក្រុមជនងាយរងគ្រោះជាក់លាក់ឬទេ ?
8. ក្នុងការកំណត់តម្រូវការអភិវឌ្ឍន៍ តើមានការចូលរួមពីអ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋឬទេ ?
9. តើគម្រោងវិនិយោគដែលបានរៀបចំ បានឆ្លើយតបទៅនឹងបញ្ហាប្រឈម ដូចរៀបរាប់នៅក្នុងការវិភាគស្ថានភាពឬទេ ?
10. តើគម្រោង ឬសកម្មភាព និងប្រតិបត្តិការសេវារដ្ឋបាលនានា ឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍខេត្ត និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានដែរឬទេ ?
11. តើគម្រោងអាទិភាពដែលមានថវិកាគាំទ្រ ឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ប្រជាពលរដ្ឋ ពិសេស ស្ត្រី ឬបុរស ឬកុមារ ឬជនពិការ ឬក្រុមជនងាយរងគ្រោះជាក់លាក់ណាមួយឬទេ ?
12. តើដំពូកតាមដានត្រួតពិនិត្យ បានកំណត់អំពីយន្តការ និងវិធីសាស្ត្រសម្រាប់ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឬទេ ?
13. តើសេចក្តីព្រាងកម្មវិធីវិនិយោគ បានយកទៅពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធឬទេ ?
14. តើគម្រោងដែលមានថវិកាគាំទ្រ មានគម្រោងហេដ្ឋារចនា សម្ព័ន្ធរូបវន្តប៉ុន្មាន ? អរូបវន្តប៉ុន្មាន ?

**ឧបសម្ព័ន្ធទី៦**

## ជំនួយស្មារតី

## សម្រាប់សរសេរអំពីស្ថានភាពទូទៅ

នៅពេលសរសេរពីស្ថានភាពទូទៅ សក្តានុពល និងបញ្ហាប្រឈមរបស់មូលដ្ឋាន (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) ក្រុមការងារកសាងផែនការ ត្រូវអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម ៖

**រៀបចំតារាងទិន្នន័យ**

តួលេខដែលយកមកបំពេញក្នុងតារាងសង្ខេបទិន្នន័យ ត្រូវស្រង់ចេញពីសៀវភៅទិន្នន័យភូមិ ឃុំ សង្កាត់ និងឯកសារព័ត៌មានស្ថានភាពមូលដ្ឋាន ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយគេ។ តួលេខមួយចំនួនដូចជា ផ្ទៃដី ចំនួនក្រុង ស្រុក ឃុំ សង្កាត់ ចំនួនភូមិ គឺក្រុមការងារកសាងផែនការត្រូវបំពេញដោយខ្លួនឯង។ ក្រុមការងារអាច បន្ថែមព័ត៌មានផ្សេងទៀត ដែលខ្លួនយល់ថាមានសារៈសំខាន់ដល់ការរំលេចគុណភាពកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់ខ្លួន ដូចជា សូចនាករនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅ និងចំណុចដៅក្នុងផែនការយុទ្ធ សាស្ត្រអភិវឌ្ឍន៍ជាតិ តែមិនគួរបន្ថែមច្រើនពេកនាំឱ្យព័ត៌មានទាំងនោះប្រែទៅជាមិនសំខាន់ទៅវិញ។

ចំពោះឆ្នាំដំបូងនៃអាណត្តិក្រុមប្រឹក្សា ទិន្នន័យត្រូវយកទិន្នន័យឆ្នាំចាស់(ឆ្នាំកន្លងទៅ)ហើយទិន្នន័យនេះ ត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ដោយបន្ថែមកូឡោនតាមឆ្នាំនីមួយៗនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល។

**ការសរសេរពីស្ថានភាពសេដ្ឋកិច្ច**

ក្នុងចំណុចនេះក្រុមការងារ ត្រូវធ្វើការកំណត់ និងសរសេរតាមបែបវិភាគអំពីសកម្មភាពសេដ្ឋកិច្ចចម្បងៗ និងបន្ទាប់បន្សំមួយចំនួន ដែលមានក្នុងមូលដ្ឋានដោយផ្អែកលើលទ្ធផលវិភាគផ្នែកសេដ្ឋកិច្ច។

សកម្មភាពសេដ្ឋកិច្ចចម្បង គឺសំដៅលើសកម្មភាពដែលប្រជាពលរដ្ឋភាគច្រើនអនុវត្ត ដើម្បីយកផលមក ធ្វើជាកម្លាំងស្នូលក្នុងការទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ ចំណែកឯសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ គឺសំដៅលើសកម្ម ភាពដែលប្រជាពលរដ្ឋមួយចំនួនអនុវត្តដើម្បីរកកម្រៃបន្ថែមសម្រាប់ការទ្រទ្រង់ជីវភាព (*ទោះបីជាបរិមាណចំណូល ពីសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំអាចច្រើនជាងចំណូលពីសកម្មភាពសេដ្ឋកិច្ចចម្បងក៏ដោយ ក៏នៅតែចាត់ទុកថា ជាសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ*)។

**ឧទាហរណ៍** ៖ ក្នុងខេត្តដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរជាអាជីវករលក់ដូរ ដូច្នេះសកម្មភាពសេដ្ឋ កិច្ចចម្បងគឺអាជីវកម្ម ទោះបីជាចំណូលពីការលក់ដូររបស់ប្រជាពលរដ្ឋម្នាក់ៗអាចមានកម្រិតទាបជាងចំណូល ពី សកម្មភាពផ្សេងក៏ដោយ។ ក្រុមការងារត្រូវវិភាគស្ថានភាពអាជីវកម្មជាក់ស្តែងក្នុងខេត្តដោយពិនិត្យពីកត្តាអ្វីខ្លះ ដែលបានជំរុញ និងអ្វីខ្លះជាឧបសគ្គដល់ការឈានឡើងទាំងចំពោះមុខ និងយូរអង្វែងរបស់វិស័យនេះក្នុងខេត្ត ហើយដែលកំពុងជះឥទ្ធិពលលើកម្រិតជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ទន្ទឹមនេះ ត្រូវបរិយាយពីអ្វីខ្លះដែលនាំ ឱ្យមានការផ្លាស់ប្តូរក្នុងមុខរបរជំនួញ( ឧទាហរណ៍: កត្តាសេដ្ឋកិច្ចប្រែប្រួល) ហើយអ្វីខ្លះដែលខេត្តត្រូវធ្វើការព្យា យាមទប់ស្កាត់ ឬគ្រប់គ្រង ការផ្លាស់ប្តូរទាំងនេះ ដើម្បីជានានិរន្តរភាព និងភាពរីកចម្រើនក្នុងវិស័យនេះ។ ចំពោះ ខេត្តដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរធ្វើស្រែ សកម្មភាពសេដ្ឋកិច្ចចម្បងសម្រាប់ខេត្តនោះ គឺកសិកម្ម ទោះបីជាចំណូលបានមកពីការធ្វើស្រែរបស់ប្រជាកសិករម្នាក់ៗអាចតិចជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។

**សកម្មភាពចម្បង**

ក្នុងផ្នែកសេដ្ឋកិច្ច រួមមាន ៖

- **អាជីវកម្ម ៖** មុខរបរសំខាន់ៗក្នុងវិស័យអាជីវកម្មរួមមាន មុខរបរជំនួញ ប្រភេទសិប្បកម្មនានា ជាងជួសជុល។ល។ ក្នុងស្ថានភាពអាជីវកម្ម ត្រូវសរសេររៀបរាប់ពីសក្តានុពលសំខាន់ៗរបស់មូល ដ្ឋាន និងបញ្ហាប្រឈមនានាដែលមូលដ្ឋានកំពុងជួបប្រទះ។

- **កសិកម្ម ៖** សកម្មភាពសំខាន់ៗក្នុងវិស័យកសិកម្មរួមមាន ការដាំដុះស្រូវ ដំណាំកសិឧស្សាហកម្ម និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វនិងត្រី ការប្រើប្រាស់ជីធ្លី និងប្រព័ន្ធធារាសាស្ត្រដែលជួយគាំទ្រដល់ការងារកសិកម្ម។ ក្នុងស្ថានភាពកសិកម្ម ត្រូវសរសេររៀបរាប់អំពីសក្តានុពលសំខាន់ៗរបស់មូលដ្ឋាននិងបញ្ហាប្រឈមនានាកំពុងជួបប្រទះនៅក្នុងមូលដ្ឋាន។
- **ឧស្សាហកម្ម ៖** សកម្មភាពសំខាន់ៗក្នុងវិស័យឧស្សហកម្មរួមមាន សកម្មភាពសិប្បកម្ម រោងចក្រ និងការងារសំណង់ជាដើម។ ដូច្នេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងវិស័យនេះ។
- **គមនាគមន៍ ៖** សរសេររៀបរាប់អំពីសក្តានុពលនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវគោក និងផ្លូវទឹក ដែលខេត្តមាន និងបញ្ហាប្រឈមសំខាន់ៗដែលមូលដ្ឋានកំពុងជួបប្រទះ។
- **សេវាកម្ម ៖** សរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមនៃសេវាកម្មនានាពាក់ព័ន្ធនឹងសាធារណការ ទឹកស្អាត អគ្គិសនី ទីផ្សារ ទេសចរណ៍ ។ល។
- **ការវិនិយោគ ៖** ចំណុចនេះត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងវិស័យឯកជនជាមួយខេត្តដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍នានាក្នុងខេត្ត ដូចជាការអភិវឌ្ឍន៍ផ្សារ ចំណតរថយន្ត ផ្លូវ ស្ពាន និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀត។ ដូច្នេះត្រូវសរសេររៀបរាប់ពីសក្តានុពល និងបញ្ហាប្រឈម ចម្បងៗដែលពាក់ព័ន្ធនឹងការវិនិយោគនេះ។
- **ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ៖** ត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយពាណិជ្ជករ ឬក្រុមហ៊ុនក្នុងខេត្ត ក្រៅខេត្ត ឬកិច្ចសហប្រតិបត្តិការ ឬការចងសម្ព័ន្ធមេត្រីជាមួយអាជ្ញាធររដ្ឋបាលនានាដើម្បីអភិវឌ្ឍន៍មូលដ្ឋានដូចជា ការបង្កើតតំបន់អភិវឌ្ឍន៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការការពារទឹកជំនន់ និងការអភិវឌ្ឍទីផ្សារជាដើម។ ដូច្នេះត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារទាំងនេះ។

ក្រៅពីចំណុចសំខាន់ដែលបានរៀបរាប់ខាងលើ ក្រុមការងារអាចបន្ថែមនូវចំណុចផ្សេងទៀត ដែលយល់ថាចាំបាច់ និងគួរបញ្ចូលក្នុងកម្មវិធីវិនិយោគ។ ការសរសេររៀបរាប់ចំណុចបន្ថែមនេះគឺដូចគ្នានឹងចំណុចនានាខាងលើដោយផ្តោតលើសក្តានុពល និងបញ្ហាប្រឈមនានា ។

**ការសរសេរពីស្ថានភាពសង្គមកិច្ច**

ស្ថានភាពសង្គមកិច្ចគឺជាផ្នែកមួយដែលត្រូវធ្វើការសិក្សាពីលក្ខណៈប្រជាសាស្ត្រ សេវាសាធារណៈផ្នែកសង្គម និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ដូចជា៖ ស្ថានភាពអប់រំ សុខុមាលភាព យេនឌ័រ ភាពក្រីក្រ អំពើហិង្សា ការជួញដូរស្ត្រីនិងកុមារ ការលើកកម្ពស់សិទ្ធិមនុស្ស និងស្ថានភាពសាសនាជាដើម។ ពេលសរសេរអំពីស្ថានភាពសង្គមកិច្ច ត្រូវសរសេរតាមបែបវិភាគដោយផ្អែកលើលទ្ធផលនៃការវិភាគសង្គមកិច្ច និងត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- **អប់រំ ៖** សរសេរពីការសម្រេចបានរបស់វិស័យអប់រំ ដូចជា៖ ការសិក្សារបស់កុមារ ស្តង់ដារអប់រំ (ការចូលរៀនរបស់កុមារនៅថ្នាក់មត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ ការបោះបង់ចោលការសិក្សា ការរៀនត្រួតថ្នាក់ ពិសេសក្មេងស្រី ការងារអក្ខរកម្ម...)។
- **សុខាភិបាល ៖** សរសេរពីស្ថានភាពសុខភាពរបស់ប្រជាជន ពិសេសស្ត្រីនិងកុមារ កម្រិតនៃការទទួលបានសេវាសុខភាព អត្រាមរណភាពមាតានិងទារក គ្រោះថ្នាក់កើតពីជំងឺផ្សេងៗ និងបញ្ហាដែលពាក់ព័ន្ធនឹងសុខភាពមាតានិងកុមារ ទឹកស្អាត អនាម័យ បញ្ហាយុវវ័យ សុខភាពបន្តពូជ ។ល។

- **យេនឌ័រ ៖** គួរសរសេរពីការទទួលយកសេវា ការចូលរួមចំណែករបស់ស្ត្រីក្នុងការសម្រេចចិត្តនានា និងសកម្មភាពសង្គម និងការលំបាកដែលស្ត្រីកំពុងជួបប្រទះ(បុរសពុំបានជួប) ឬកត្តាទាំងឡាយក្នុងសង្គម ដែលនាំឱ្យស្ត្រីជួបការលំបាកញឹកញាប់ជាងបុរស។
- **ភាពក្រីក្រ ៖** សរសេរពីកម្រិតក្រីក្ររបស់ប្រជាជនដោយបង្ហាញពីមូលហេតុចម្បងៗដែលនាំឱ្យមានគ្រួសារមួយចំនួនធ្លាក់ខ្លួនក្រ មូលហេតុដែលគ្រួសារក្រីក្រមិនអាចកែលម្អជីវភាពរបស់ពួកគេបាន និងមូលហេតុដែលនាំឲ្យគ្រួសារក្រីក្របានកែលម្អជីវភាពខ្លួន។
- **សាសនា ៖** រៀបរាប់ពីប្រភេទសាសនា និងចំនួនភាគរយប្រជាពលរដ្ឋ ដែលកាន់សាសនានីមួយៗ។
- **អន្តោប្រវេសន៍ និងការផ្លាស់ប្តូរទីលំនៅ ៖** ត្រូវសរសេររៀបរាប់ពីស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅរបស់ប្រជាពលរដ្ឋពីតំបន់ផ្សេងៗចូលមកមូលដ្ឋានខ្លួនដើម្បីប្រកបមុខរបរនានា ដូចជា ៖ ប្រកបមុខរបរជាកម្មកររត់ម៉ូតូឌុប កម្មកររោងចក្រ និងជនបរទេសដែលចូលមកជាអ្នកទេសចរ ឬមកប្រកបមុខរបរ។ ចំណុចនេះ ត្រូវសរសេររៀបរាប់ពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងស្ថានភាពទាំងនេះ។

ក្រៅពីស្ថានភាពសំខាន់ៗខាងលើ ក្រុមការងារអាចធ្វើការរៀបរាប់បន្ថែមពីស្ថានភាពផ្សេងទៀត ដែលពាក់ព័ន្ធនឹងស្ថានភាពសង្គមកិច្ច តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន ដូចជាការលើកកម្ពស់សិទ្ធិកុមារ និងប្រជាពលរដ្ឋទូទៅ ការទប់ស្កាត់សកម្មភាពជួញដូរស្ត្រីនិងកុមារ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការជួយជនចាស់ជរាគ្មានទីពឹង និវត្តជន កុមារកំព្រាជនអនាថា។ល។

### ការសរសេរពីស្ថានភាពធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ផ្នែកនេះត្រូវសរសេររៀបរាប់ពីអ្វីខ្លះដែលជាភាពខ្លាំង(សក្តានុពល)និងផលប្រយោជន៍ ដែលមានដូចជាដីធ្លីនិងធនធានធម្មជាតិ និងអ្វីខ្លះដែលជាបញ្ហាប្រឈម ឬឧបសគ្គដែលកំពុងគំរាមកំហែងដល់ដីធ្លី ធនធានធម្មជាតិនិងបរិស្ថាន។ ទន្ទឹមនេះ ត្រូវសរសេររៀបរាប់ពីគ្រោះថ្នាក់ ការបាត់បង់ខូចខាត ការបំផ្លិចបំផ្លាញ ការប្រែប្រួល និងផលប៉ះពាល់ជាអវិជ្ជមានពីបាតុភូតទាំងឡាយកើតមានឡើង ដែលបង្កដោយមនុស្ស ឬដោយធម្មជាតិ។

ការសរសេរផ្នែកនេះត្រូវផ្អែកលើលទ្ធផលនៃការវិភាគការប្រើប្រាស់ដីធ្លី ការវិភាគធនធានធម្មជាតិ ការវិភាគបរិស្ថាន និងការវិភាគគ្រោះមហន្តរាយ ដោយផ្តោតលើ៖

- **ការប្រើប្រាស់ដីធ្លី ៖** ត្រូវរៀបរាប់ពីបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីលំនៅដ្ឋាន ដីធ្វើស្រែ ដីចំការ ដីសម្រាប់ការវិនិយោគ ដីសម្បទាន តំបន់អភិរក្ស។ល។ ចំពោះការប្រើប្រាស់ដីសម្រាប់លំនៅដ្ឋាន ត្រូវរៀបរាប់ពីសក្តានុពលនិងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការកំណត់ប្រភេទលំនៅដ្ឋាន ការផ្លាស់ប្តូរទីតាំង ការរៀបចំនិងគ្រប់គ្រងសំណង់អានាធិបតេយ្យ និងការរៀបចំប្លង់លំនៅដ្ឋានជាដើម។ល។
- **ធនធានធម្មជាតិ ៖** បរិយាយពីធនធានធម្មជាតិសំខាន់ៗ ដែលមាន ដូចជា ៖ ដីធ្លី ព្រៃឈើ សត្វព្រៃ ធនធានជលផល បឹង អូរ ស្ទឹង រ៉ែ...។ល។ ដែលប្រជាជនពឹងផ្អែកលើធនធានទាំងនេះសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ ដូច្នេះ ត្រូវសរសេរពីកម្រិតនៃការប្រើប្រាស់ធនធានទាំងនេះ និងបញ្ហាប្រឈមចម្បងៗដែលកំពុងជួបប្រទះពាក់ព័ន្ធនឹងការប្រើប្រាស់នេះ។
- **បរិស្ថាន ៖** ត្រូវរៀបរាប់ពីសក្តានុពលពាក់ព័ន្ធនឹងបរិស្ថាន ដូចជាកន្លែងហាត់ប្រាណ និងសួនឧទ្យានសាធារណៈ ទីលានចាក់សំរាម និងបញ្ហានានា ដែលគំរាមកំហែងលើបរិស្ថាន ដូចជាការបំពុលបរិយាកាស កាកសំណល់រឹង និងរាវ។ល។

- **គ្រោះមហន្តរាយចម្បងៗ ៖** រៀបរាប់ពីស្ថានភាពនៃការបំផ្លិចបំផ្លាញដោយសារខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ភ្លើងឆេះផ្ទះ គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ គ្រោះទឹកជំនន់។ល។
- **ការប្រែប្រួលអាកាសធាតុ ៖** រៀបរាប់ពីទឹកជំនន់ ភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនទៀងទាត់។

**ការសរសេរពីស្ថានភាពរដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ផ្នែកនេះត្រូវសរសេររៀបរាប់ដោយសង្ខេបពីចំណុចសំខាន់ៗដូចជា ៖ អភិបាលកិច្ច ការគ្រប់គ្រងដែនដី ស្ថិតិប្រជាជន កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពរដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ទិន្នន័យនិងព័ត៌មានមួយចំនួន ដែលត្រូវរៀបរាប់ក្នុងផ្នែកនេះ មានបង្ហាញក្នុងតារាងព័ត៌មានសំខាន់ៗ ដូចជា ចំនួនក្រុង ស្រុក ឃុំ សង្កាត់ ភូមិ និងស្ថិតិប្រជាជន។

- **អភិបាលកិច្ច ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងអភិបាលកិច្ច។
- **គ្រប់គ្រងដែនដី៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំ និងគ្រប់គ្រងដែនដីរដ្ឋបាល ដូចជា៖ ការកំណត់ព្រំប្រទល់ដែនដីភូមិសាស្ត្ររដ្ឋបាល និងតំបន់សំខាន់ៗក្នុងមូលដ្ឋាន ការបង្កើតក្រុង ស្រុក ឃុំ សង្កាត់ និងភូមិថ្មី ការរៀបចំប្លង់គោលជាដើម។
- **ការគ្រប់គ្រងស្ថិតិ៖** រៀបរាប់ពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការចុះបញ្ជី និងការងារអត្រានុកូលដ្ឋាន។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រង ការរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ នៅតំបន់ទីប្រជុំជនសំខាន់ៗ។

**ចំពោះខេត្តជាប់ព្រំដែន គួរបញ្ចូលការងារព្រំដែន ៖** ភាពងាយស្រួល និងការលំបាកក្នុងការរៀបចំ និងគ្រប់គ្រងច្រកព្រំដែន និងកិច្ចសហការជាមួយប្រទេសជិតខាង។

## ឧបសម្ព័ន្ធទី៧

## ឧបករណ៍
## វិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

ការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្ត រាយទៅក្នុងកម្មវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើសេចក្តីណែនាំបច្ចេកទេសស្តីពីការ រៀបចំកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ។ ដំណើរការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ត្រូវអនុវត្តឡើងតាំងពីដំណាក់កាលដំបូងនៃការរៀបចំកម្មវិធី វិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

នៅក្នុងការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះ មហន្តរាយ ក្រុមការងារកសាងផែនការ គ.ផ.ថ និង ឬ អ្នកពាក់ព័ន្ធផ្សេងៗទៀត អាចប្រើប្រាស់ឧបករណ៍ នានា ដូចខាងក្រោម ៖

### ១). ឧបករណ៍ទី១ ៖ ការគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ

ការរៀបចំផែនទីនេះនឹងជួយកំណត់ពីមុខសញ្ញាហានិភ័យនៃគ្រោះមហន្តរាយ ដែលបានកើតឡើងក្នុងមូលដ្ឋាន។ ការគូរផែនទីនឹងជួយដល់អ្នករៀបចំផែនការក្នុងការកំណត់នូវទីតាំង និងស្ថានភាពនៃភាពងាយរងគ្រោះ ដើម្បីឈានទៅធ្វើការវិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ការគូសផែនទីនេះនឹងធ្វើឡើងនៅក្នុងកម្រិតឃុំ សង្កាត់ ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សា គ.ក.ន.ក ប្រធានភូមិ និងអ្នកពាក់ព័ន្ធនានា ដោយប្រើប្រាស់ផែនទីរដ្ឋបាលឃុំជាគោល។

ការគូសផែនទីត្រូវធ្វើឡើងជា៤ជំហាន ដូចខាងក្រោម ៖

- **ជំហានទី១ ៖** គូសគំនូសទ្រង់ទ្រាយរបស់រដ្ឋបាលឃុំ សង្កាត់ កំណត់ព្រំប្រទល់រដ្ឋបាលភូមិ រួចហើយអ្នកចូលរួមគូសបន្ថែមនូវទីតាំងលក្ខណៈធម្មជាតិដូចជា ទន្លេ បឹង ព្រៃ តំបន់អភិរក្សជាដើម។
- **ជំហានទី២ ៖** គូសបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធថ្មីៗដែលមានក្នុងមូលដ្ឋានទៅក្នុងផែនទី ដូចជា ៖
  - ផ្លូវ
  - អគារសាធារណៈ (វត្ត អគាររដ្ឋបាល សាលារៀន មន្ទីរពេទ្យ...)
  - ទំនប់ទឹក អាងស្តុកទឹក ប្រព័ន្ធធារាសាស្ត្រ អណ្តូងទឹក និងស្រះ
  - ហេដ្ឋារចនាសម្ព័ន្ធអគ្គីសនី (ម៉ាស៊ីនភ្លើង, ឋាមពលកកើតឡើងវិញ...)
  - ទីតាំងចាក់សំរាម ប្រព័ន្ធលូ
  - បូជនីយដ្ឋាន ជាដើម
- **ជំហានទី៣ ៖** ក្នុងជំហាននេះ អ្នកចូលរួមគូសផែនទីបញ្ជាក់ពីទីតាំងដែលទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិ ដោយប្រើប្រាស់គំនូសតាងផ្សេងៗគ្នា ឬប្រើប្រាស់ពណ៌ជាសញ្ញាតាមការឯកភាពគ្នាក្នុងក្រុម។ ផលប៉ះពាល់អាចមានដូចជា តំបន់ដែលរងផលប៉ះពាល់ពីទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះ សត្វល្អិតបំផ្លាញ ជម្ងឺរាតត្បាត ការឡើងកំដៅ និងតំបន់ឆ្នេរដែលមានរលកធំៗ ជាដើម។
- **ជំហានទី៤ ៖** អ្នកចូលរួមកំណត់ និងគូសលើផែនទីពីស្ថានភាពប្រែប្រួលនៃទិដ្ឋភាពពីមុន និងពេលបច្ចុប្បន្ន (ឧទាហរណ៍ ៖ ទំនប់តាមតំបន់ឆ្នេរ ការបាត់បង់ព្រៃ និងដីអភិរក្ស)។ ការប្រែប្រួលទាំងនេះអាចមានប្រភពខុសគ្នាៗដូចជា បណ្តាលមកពីការសម្រេចចិត្តផ្នែកនយោបាយ សង្គម សេដ្ឋ

កិច្ច ផលប៉ះពាល់ពីអាកាសធាតុ និងពីគ្រោះធម្មជាតិជាដើម។ ទោះជាមានហេតុផលខុសគ្នាក៏ដោយ ការប្រែប្រួលនៃបរិស្ថានធម្មជាតិ ក៏អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការប្រែប្រួលអាកាសធាតុ ឬគ្រោះធម្មជាតិផងដែរ។

**តាមរយៈឧបករណ៍ទី១នេះ** អ្នកវិភាគអាចកំណត់បាននូវទីតាំងភូមិសាស្ត្រ ប្រភេទគ្រោះមហន្តរាយធម្មជាតិ ស្ថានភាពនៃការប្រែប្រួល និងមូលហេតុនានាដែលនាំឲ្យ មានការប្រែប្រួលស្ថានភាពគ្រោះធម្មជាតិតាមប្រភេទនីមួយៗ។ ឧបករណ៍ទី១នេះ នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការអនុវត្ត ឧបករណ៍ផ្សេងៗទៀត។

## ២). **ឧបករណ៍ទី២ ៖ ការវិភាគនិន្នាការ**

ការវិភាគនិន្នាការ គឺជាឧបករណ៍សម្រាប់កំណត់នូវការប្រែប្រួលអាកាសធាតុសំខាន់ៗ និងព្រឹត្តការណ៍គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុដែលកើតមានឡើង។ លទ្ធផលនៃការវិភាគនេះនឹងផ្តល់នូវព័ត៌មានអំពីគ្រោះមហន្តរាយអាកាសធាតុជាក់លាក់ និន្នាការនៃប្រភេទគ្រោះមហន្តរាយធម្មជាតិនីមួយៗ ភាពញឹកញាប់ ភាពធ្ងន់ធ្ងរ និងរបបនៃផលប៉ះពាល់។

ការអនុវត្តនូវឧបករណ៍វិភាគនិន្នាការនេះ ត្រូវធ្វើឡើងជាមួយប្រជាពលរដ្ឋ ដែលស្ថិតក្នុងតំបន់រងគ្រោះពីគ្រោះមហន្តរាយ (ផ្អែកលើផែនទីហានិភ័យគ្រោះមហន្តរាយ) ជនងាយរងគ្រោះ ស្ត្រី ចាស់ជរា និងជនក្រីក្រដោយបែងចែកជាក្រុមពិភាក្សាតូចៗយ៉ាងតិច៣ ដូចជាក្រុមស្ត្រី ក្រុមបុរស និងក្រុមអាជ្ញាធរ ឬច្រើនជាងនេះទៅតាមការចាំបាច់។ ការវិភាគធ្វើឡើងជា៣ជំហាន ដូចខាងក្រោម ៖

- **ជំហានទី១ ៖** អ្នកសម្របសម្រួលត្រូវសួរអំពីព្រឹត្តការណ៍គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ និងផលប៉ះពាល់ដែលពួកគេបានជួបប្រទះកន្លងមក ហើយយកទិន្នន័យនោះទៅបំពេញនៅក្នុងតារាងខាងក្រោមត្រង់ខ្ទង់ លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស (ដូចមានក្នុងតារាងខាងក្រោម)។
- **ជំហានទី២ ៖** អ្នកសម្របសម្រួលបន្តសាកសួរដល់អ្នកចូលរួមធ្វើការចាត់ថ្នាក់ភាពងាយរងគ្រោះដែលបានជួបប្រទះតាមឆ្នាំ ដែលបានកំណត់ទៅតាមមុខសញ្ញានៃគ្រោះមហន្តរាយនីមួយៗ។ ក្នុងការធ្វើចំណាត់ថ្នាក់នេះត្រូវដាក់ពិន្ទុ កម្រិតរងគ្រោះពី១ ដល់៥ (១.កម្រិតរង គ្រោះទាបបំផុត និង៥.ជាកម្រិតរងគ្រោះធ្ងន់ធ្ងរបំផុត)។
- **ជំហានទី៣ ៖** បន្ទាប់ពីការដាក់ពិន្ទុកម្រិតភាពរងគ្រោះហើយ ត្រូវបន្តពិនិត្យមើលលើនិន្នាការនៃផលប៉ះពាល់ទៅតាមមុខសញ្ញានីមួយៗ ហើយស្វែងរកនូវមុខសញ្ញាគ្រោះថ្នាក់ណាមួយដែលកើតឡើងញឹកញាប់ និងកាន់តែធ្ងន់ធរ ដើម្បីធ្វើការវិភាគបន្តនៅក្នុងទម្រង់អក្សរ H។

តារាងវិភាគនិន្នាការ

| ប្រភេទគ្រោះធម្មជាតិ | និន្នាការ | | | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | ១៩៨០-៨៩ | ១៩៩០-៩៩ | ២០០០-០៩ | ២០១០-បច្ចុប្បន្ន | |
| • រាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • រដូវប្រាំងអូស បន្លាយ (លើសពី៣សប្តាហ៍) | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការខូតដំណាំ ដោយភាពរាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការខូតដំណាំ ដោយទឹកជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |

| ប្រភេទគ្រោះធម្មជាតិ | និន្នាការ | | | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | ១៩៨០-៨៩ | ១៩៩០-៩៩ | ២០០០-០៩ | ២០១០-បច្ចុប្បន្ន | |
| • ការធ្លាក់ភ្លៀងខ្លាំង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការកើនឡើងកម្រិតទឹកជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការអូសបន្លាយ រយៈពេលទឹក ជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការប្រែប្រួល អំឡុងពេលរដូវ ប្រាំង - វស្សា | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ។ល។ | | | | | |

**កំណត់សម្គាល់**

ក្នុងការអនុវត្តជាក់ស្តែង អ្នកវិភាគត្រូវពិចារណាលើកំណត់សម្គាល់ដូចខាងក្រោម ៖

- ប្រភេទគ្រោះធម្មជាតិ ៖ អាស្រ័យលើប្រភេទគ្រោះធម្មជាតិដែលបានកើតមានឡើងជាក់ស្តែងនៅក្នុងមូលដ្ឋាននីមួយៗ។
- ឆ្នាំ ៖ អាចកំណត់ ឬបែងចែកតាមជំនាន់ ឬរបប ឬឆ្នាំ ឬតាមការកំណត់ផ្សេងៗទៀត ដែល ជាអាចឲ្យអ្នកចូលរួមងាយស្រួលក្នុងការរំលឹកឡើងវិញនូវនិន្នាការពាក់ព័ន្ធនឹងប្រភេទគ្រោះធម្មជាតិនីមួយៗ។

៣). **ឧបករណ៍ទី៣ ៖ ការវិភាគតាមទម្រង់** H

ឧបករណ៍ទម្រង់អក្សរ "H" គឺជាឧបករណ៍វាយតម្លៃដោយមានការចូលរួម ដែលពង្រឹងបន្ថែមលើលទ្ធផលនៃការវិភាគនិន្នាការ ហើយឧបករណ៍នេះមានគោលបំណងកំណត់ភាពប្រែប្រួលសំខាន់នៃអាកាសធាតុ និងព្រឹត្តការណ៍គ្រោះមហន្តរាយអាកាសធាតុ ព្រមទាំងផលប៉ះពាល់ក្នុងមូលដ្ឋាននៅតំបន់ជាក់លាក់ណាមួយ។ លើសពីនេះ ឧបករណ៍នេះក៏ជួយសម្រួលផងដែរក្នុងការកំណត់វិធានការបន្សាំដែលសមស្របសម្រាប់សហគមន៍។ ក្នុងការអនុវត្តជំហាននេះ អ្នកវិភាគត្រូវអនុវត្តតាមជំហាននានា ដូចខាងក្រោម ៖

- **ជំហានទី១ "ការកំណត់ផលប៉ះពាល់នៃមុខសញ្ញាគ្រោះមហន្តរាយ"៖** សកម្មភាពក្នុងជំហាននេះ រួមមាន ៖
  - កំណត់ និងឯកភាពលើមុខសញ្ញា ឬប្រភេទគ្រោះមហន្តរាយធម្មជាតិ
  - វិភាគនិន្នាការនៃមុខសញ្ញា ឬប្រភេទគ្រោះមហន្តរាយធម្មជាតិ ដោយសួរសំណួរគន្លឹះ មួយចំនួន ដូចខាងក្រោម ៖
    - + តើមានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ កើតចេញពីមុខសញ្ញានៃគ្រោះមហន្តរាយ?
    - + តើមានដំណោះស្រាយអ្វីខ្លះ?
    - + តើផលប៉ះពាល់ មានកម្រិតណា?
    - + តើនៅក្នុងសហគមន៍មានធនធានអ្វីខ្លះ សម្រាប់ដោះស្រាយបញ្ហាប្រឈមផលប៉ះពាល់ទាំងនោះ?។ល។
  - បន្ទាប់ពីសួរសំណួរគន្លឹះនានាហើយ អ្នកសម្របសម្រួលត្រូវ ៖
    - + ស្រង់នូវផលប៉ះពាល់អវិជ្ជមានដែលបានលើកឡើងដោយអ្នកចូលរួមទៅក្នុងផ្នែកខាងឆ្វេងនៃតារាងទម្រង់ H
    - + ស្រង់ពីធនធានដែលមានក្នុងសហគន៍ដាក់នៅផ្នែកខាងស្តាំនៃតារាងទម្រង់ H
    - + ស្រង់អំពីដំណោះស្រាយដែលបានលើកឡើងនៅផ្នែកកណ្តាលនៃតារាងទម្រង់ H

- បន្ទាប់មកទៀត អ្នកសម្របសម្រួលស្នើសុំឲ្យអ្នកចូលរួមវាយតម្លៃពីកម្រិតផលប៉ះពាល់នៃមុខសញ្ញាវងគ្រោះនោះចំពោះរូបគេ និងក្រុមគ្រួសារម្នាក់ម្តងៗ តាមរយៈការដាក់ពិន្ទុពី ១ជាកម្រិតទាប ដល់៥ដែលជាកម្រិតធ្ងន់ធ្ងរ។ រួចធ្វើការគណនាមធ្យមភាគពិន្ទុដែល អ្នកចូលរួមបានដាក់។

ការវិភាគតាមទម្រង់ H ទី១

បញ្ហា ៖ ....................................................

| ផលប៉ះពាល់ ៖ | ដំណោះស្រាយ<br><br>១ ២ ៣ ៤ ៥ | ធនធានដែលមាន ៖ |
|---|---|---|
| + | + | + |
| + | + | + |
| + | + | + |

- បន្ទាប់ពីអ្នកចូលរួមនីមួយៗបានដាក់ពិន្ទុលើកម្រិតនៃផលប៉ះពាល់ហើយ អ្នកសម្របសម្រួលត្រូវបូកសរុប និងគិតមធ្យមភាគលើពិន្ទុដែលបានកំណត់។ ពិន្ទុមធ្យមភាគដែល បានកំណត់ត្រូវប្រើប្រាស់ជាសូចនាករសម្រាប់តាមដានអំពីវឌ្ឍនភាពនៃការឆ្លើយតបទៅ នឹងការបន្សាំការប្រែប្រួលអាកាសធាតុ និងជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់ចាត់អាទិភាពលើបញ្ហាដែលត្រូវដោះស្រាយ

- **ជំហានទី២ "ការកំណត់ផលប៉ះពាល់ពីការកើនឡើងទ្វេដងនៃមុខសញ្ញាគ្រោះមហន្តរាយ" ៖** នៅក្នុងជំហានទី២នេះ អ្នកសម្របសម្រួលលើកឡើងថា ប្រសិនបើមុខសញ្ញានៃគ្រោះមហន្តរាយ (មុខសញ្ញាដែលបានវិភាគក្នុងជំហានទី១) កើនឡើងកាន់តែញឹកញាប់ ឬកើនឡើងទ្វេដង តើប្រជាពលរដ្ឋម្នាក់ ឬគ្រួសារនីមួយៗនឹងទទួលផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ? ហើយគួរត្រូវមានដំណោះស្រាយយ៉ាងដូចម្តេច? អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់អ្នកចូលរួមនៅក្នុងទម្រង់ H ដូចខាងក្រោម ៖

ការវិភាគតាមទម្រង់ H ទី២

បញ្ហា ៖ ....................................................

| ផលប៉ះពាល់ ៖ | ដំណោះស្រាយ ៖<br><br>១ ២ ៣ ៤ ៥ | |
|---|---|---|
| + | + | |
| + | + | |
| + | + | |

បន្ទាប់មក អ្នកសម្របសម្រួលស្នើឲ្យអ្នកចូលរួមដាក់ពិន្ទុលើកម្រិតផលប៉ះពាល់ ដូចជំហានទី១។ ទម្រង់អក្សរ Hទី២នេះនឹងជួយឲ្យអ្នកចូលរួមគិតប្រមាណទុកជាមុននូវភាពធ្ងន់ធ្ងរនៃអាកាសធាតុដែលអាចគម្រាមគំហែងដល់សហគមន៍ និងលើកយកដំណោះស្រាយកាន់តែមានប្រសិទ្ធភាពមួយកម្រិតថែមទៀត ក្នុងការបង្ការផលប៉ះពាល់ពីគ្រោះមហន្តរាយ កសាងភាពធន់ និងការបន្សាំខ្លួនរបស់សហគមន៍។

- **ជំហានទី៣ "ការកំណត់កត្តារាំង" ៖** បន្ទាប់មកអ្នកសម្របសម្រួលបន្តពិភាក្សាអំពី ឧបសគ្គនានាដែលអាចកើតមានឡើង ដោយប្រើឧបករណ៍ទម្រង់អក្សរ H ទី៣។ ក្នុងការប្រើប្រាស់ឧបករណ៍ H ទី៣នេះ អ្នកសម្រសបម្រួល ផ្តោតលើកត្តារាំងនានា ដែលប្រជាពលរដ្ឋ ឬសហគមន៍មិនអាចបន្សាំទៅនឹងមុខសញ្ញានៃគ្រោះមហន្តរាយដែលត្រូវបានលើកឡើងមកនោះ។ ចម្លើយរបស់អ្នកចូលរួមត្រូវកត់ត្រាទុកនៅផ្នែកកណ្តាលនៃតារាង ហើយអ្នកចូលរួមត្រូវដាក់ពិន្ទុនៃកម្រិតកត្តារាំងនោះម្នាក់ម្តងៗពីលេខ១ជាកម្រិតតិចតួច ដល់លេខ៥ជាកម្រិតធ្ងន់ធ្ងរ។ ចុងបញ្ចប់ត្រូវគណនានូវពិន្ទុមធ្យមភាគនៃការដាក់ពន្ទុរបស់អ្នកចូលរួម។

ការវិភាគតាមទម្រង់ H ទី៣




- **ជំហានទី៤ "ការកំណត់វិធានការ" ៖** បន្ទាប់មកអ្នកសម្របសម្រួលបន្តពិភាក្សាអំពីសកម្មភាព ឬវិធានការនានា ដែលអាចជួយឲ្យប្រជាពលរដ្ឋ និងគ្រួសារនីមួយៗអាចបន្សាំទៅនឹងមុខសញ្ញានៃមហន្តរាយធម្មជាតិ ដូចដែលបានវិភាគក្នុងជំហានទី៣ ដោយសួរសំណួរគន្លឹះ ថា ៖
  - តើមានវិធានការបន្សាំអ្វីខ្លះដែលអាចជួយបង្កើនភាពធនរបស់សហគមន៍បាន?
  - តើត្រូវធ្វើយ៉ាងដូចម្តេចខ្លះ ដើម្បីឲ្យទទួលបានពិន្ទុកាន់តែល្អជាងនេះ?

  ជាមួយគ្នានេះ អ្នកសម្របសម្រួលត្រូវស្រង់ចម្លើយនៃសំណួរទាំងនេះដាក់ក្នុងផ្នែកកណ្តាលនៃទម្រង់ H និងត្រូវស្រង់ដំណោះស្រាយនានាដែលបានកំណត់ក្នុងជំហានទី២ មកដាក់បញ្ចូល និងបន្ស៊ីជាមួយគ្នា។ ព្រមទាំងធ្វើការដាក់ពិន្ទុដោយឯកភាពគ្នាជាក្រុមលើការទុកចិត្តនៃគម្រោង ឬដំណោះស្រាយដែលបានលើកឡើង ពីពិន្ទុ១ ដែលពិន្ទុទុកចិត្តខ្លាំងដល់ពិន្ទុ៥ ជាពិន្ទុមិនទុកចិត្តសោះ។

  **ការគណនាពិន្ទុ៖**

  ការគណនាពិន្ទុមធ្យមភាគនៃទម្រង់Hនីមួយៗ ត្រូវយកពិន្ទុសរុប ចែកនឹងចំនួនអ្នកដាក់ពិន្ទុ ឬគណនាតាមមធ្យាបាយផ្សេងៗទៀតតាមការចាំបាច់។

- **ជំហានទី៥ "ការរៀបចំគម្រោង" ៖** ក្រោយពីបានពិភាក្សាតាមក្រុមរួចរាល់ហើយ អ្នកសម្របសម្រួលយកលទ្ធផលនៃការកិច្ចពិភាក្សាក្រុមទាំងអស់ដាក់បញ្ចូលគ្នា ដោយស្រង់យកនូវដំណោះស្រាយ

នានាដែលបានលើកឡើង មករៀបចំជាគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ។ ចំណែកឯពិន្ទុនៃការពិភាក្សាក្នុងក្រុមនីមួយៗ ត្រូវយកមកបូកបញ្ចូលគ្នា ចែកនឹងចំនួនក្រុមពិភាក្សា នឹងបានជាពិន្ទុមធ្យមភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក្នុងឃុំ សង្កាត់ ដែលត្រូវបានកំណត់ជាសូចនាករសម្រាប់តាមដានក្នុងឆ្នាំបន្ទាប់។ ក្រោយពីបានរៀបចំជាគម្រោងបន្សាំការប្រែប្រួលអាកាសធាតុរួចរាល់ហើយ អ្នកវិភាគត្រូវជួបប្រជុំគ្នាជាថ្មីដើម្បីធ្វើការចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោង ដោយប្រើប្រាស់ឧបករណ៍ទី៤។

## ៤. ឧបករណ៍ទី៤ "ការធ្វើចំណាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោង"

ការចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងដែលបានលើកឡើង គឺជាការចាំបាច់ក្នុងការកំណត់ នូវអាទិភាពនៃគម្រោងដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់ការកៀរគរដៃគូគាំទ្រ។ ការ ចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងនីមួយៗធ្វើឡើងដោយផ្អែកលើសំណួរ និងកម្រិតដូចខាងក្រោម៖

- តើគម្រោងដែលស្នើអាចជួបប្រទះព្រឹត្តិការណ៍គ្រោះមហន្តរាយញឹកញាប់ប៉ុនណា?
  - មិនដែលជួបប្រទះ
  - កម្រនឹងជួបប្រទះ (តិចជាង០៥ឆ្នាំម្តង)
  - ជាញឹកញាប់ (យ៉ាងហោចណាស់២ទៅ៥ឆ្នាំម្តង)
  - តែងតែជួបប្រទះ (យ៉ាងហោចណាស់១ឆ្នាំម្តង)
- តើរំពឹងទុកថា អាចនឹងមានការខូចខាតអ្វីខ្លះ? (ជាការខូចខាតលើហេដ្ឋារចនាសម្ព័ន្ធ...)
  - មិនមាន
  - ខូចខាតតិចតួច
  - ខូចខាតទ្រង់ទាយ
  - ខូចខាតទាំងស្រុង

លទ្ធផលនៃការវិភាគនេះត្រូវយកមកផ្ទុផ្តងនៅក្នុងតារាងដូចខាងក្រោម ៖

# តារាងការធ្វើចំណាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ

| ល.រ | ឈ្មោះគម្រោង | ប្រភេទ | ទីតាំង | ទីតាំងនៅក្នុងតំបន់ហានិភ័យ | | ភាពញឹកញាប់នៃផលប៉ះពាល់ | | | | ការខូចខាត | | | | ប្រភេទនៃភាពងាយរងគ្រោះ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មាន | មិនមាន | មិនដែល | កម្រមាន | ញឹកញាប់ | ជាប្រចាំ | មិនមាន | ខូចខាត តិចតួច | ខូចខាតខ្លាំង | ខូចទាំងស្រុង | |
| | | | | | | X | | | | x | | | | មិនមានហានិភ័យ |
| | | | | | | | X | | | | x | | | មានហានិភ័យទាប |
| | | | | | | | | x | | | | x | | មានហានិភ័យមធ្យម |
| | | | | | | | | | x | | | | x | មានហានិភ័យខ្ពស់ |
| | | | | | | | X | | | x | | | | មិនមានហានិភ័យ |
| | | | | | | | X | | | | | x | | មានហានិភ័យមធ្យម |
| | | | | | | | X | | | | | | x | មានហានិភ័យខ្ពស់ |
| | | | | | | | | x | | x | | | | មិនមានហានិភ័យ |
| | | | | | | | | x | | | x | | | មានហានិភ័យមធ្យម |
| | | | | | | | | x | | | | | x | មានហានិភ័យខ្ពស់ |
| | | | | | | | | | x | x | | | | មិនមានហានិភ័យ |
| | | | | | | | | | x | | x | | | មានហានិភ័យខ្ពស់ |
| | | | | | | | | | x | | | x | | មានហានិភ័យខ្ពស់ |